TRANSPARENCY INTERNATIONAL Cambodia

ខែ មករា ឆ្នាំ 2024

# ការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការរៀបចំផែនការថវិកាសម្រាប់ឆ្នាំសារពើពន្ធបន្ទាប់

## មតិយោបល់ពីក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលលើច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ 2024

### ទិដ្ឋភាពទូទៅនៃថវិការដ្ឋឆ្នាំ2024៖ ចំណូល ចំណាយ និងឱនភាពថវិការដ្ឋ

ការចំណាយរបស់រដ្ឋឆ្នាំ 2024
(ឯកតា លានរៀល)




ប្រភពចំណូលនៃឱនភាពថវិកាឆ្នាំ 2024
(ឯកតា លានរៀល)




- ផលិតផលក្នុងស្រុកសរុប (GDP) របស់ប្រទេសកម្ពុជានៅឆ្នាំ**2023** ត្រូវបានប៉ាន់ស្មានកើនដល់ **5.6%** និងព្យាករណ៍ថាកើនឡើងដល់ **6.6%** ក្នុងឆ្នាំ **2024** ដែលឈានដល់ចំនួន **142,957** ពាន់លានរៀល ឬ **35.16** ពាន់លានដុល្លាអាមេរិក
- យុទ្ធសាស្ត្រអាទិភាព នៃថវិកាឆ្នាំ**2024**
  - ពង្រឹងសេវាថែទាំសុខភាព
  - ការពង្រីកបន្ថែមនូវជំនាញវិជ្ជាជីវៈ និងជំនាញបច្ចេកទេស សម្រាប់ក្រុមជនក្រីក្រ និងក្រុមដែលមិនសូវទទួលបានការយកចិត្តទុកដាក់
  - ដាក់ចេញនូវកម្មវិធីជំនួយសង្គមដល់គ្រួសារងាយរងគ្រោះ
  - ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈកិច្ចគាំទ្រហិរញ្ញវត្ថុ
- ការចំណាយថវិការដ្ឋឆ្នាំ **2024**៖ **9,129.25** លានដុល្លាអាមេរិក ដែលធ្លាក់ចុះចំនួន **5.3%** បើធៀបទៅនឹងឆ្នាំ **2023**។ ការចំណាយមូលធនបានធ្លាក់ចុះគួរឱ្យកត់សម្គាល់ចំនួន **31%** ដោយសារការទូទាត់បំណុលសាធារណៈ មិនបានកត់ត្រាក្នុងចំណាយមូលធន។
- ចំណូលថវិការដ្ឋឆ្នាំ**2024** មានចំនួន **7,997.27** លានដុល្លា ដែលធ្លាក់ចុះចំនួន **11.6%** បើធៀបនឹងឆ្នាំមុន
- ឱនភាពថវិការដ្ឋឆ្នាំ**2024**៖ **12.29%** ដែលស្មើនឹង **3.22%** នៃ ផ.ស.ស ខណៈដែលឆ្នាំ**2023**មានដល់ **25%**
- ចំណាយថវិការដ្ឋឆ្នាំ**2024**៖ មានការធ្លាក់ចុះ **5.3%** តែចំណាយចរន្តបានកើនឡើងចំនួន **12.9%** ស្របពេលដែលចំណាយមូលធនធ្លាក់ចុះចំនួន **31%**

## ចំណូលសរុបថវិការដ្ឋ និង ចំណាយសរុបថវិការដ្ឋ ចាប់ពីឆ្នាំ 2019 ដល់ 2024 ( គិតជា លានរៀល )




- ចំណូលហិរញ្ញប្បទានក្នុងស្រុកសម្រាប់ការវិនិយោគសាធារណៈ ដែលត្រូវបានចាត់ប្រភេទនៅក្រោមចំណាយមូលធន មានការធ្លាក់ចុះខ្លាំងចំនួន 39%
- ចំណូលចរន្តបន្តកើនឡើងរហូតដល់ 11.1% ហើយចំណាយចរន្តក៏កើនឡើងដល់ 12.9%  ការកើនឡើងនេះនាំឱ្យមានការធ្លាក់ចុះអតិរេកចរន្ត ពី 4% ក្នុងឆ្នាំ2023 ទៅ 3.79% ក្នុងឆ្នាំ2024។

## បំណុលសាធារណៈ

លានដុល្លា សហរដ្ឋអាមេរិក

| សេចក្តីបរិយាយ | 2022(Q1-Q2) | 2023(Q1-Q2) | | | | | ប្រែប្រួលជា % (2022-2023 នៃ Q1-Q2) |
|---|---|---|---|---|---|---|---|
| | សរុប | សរុប | ប្រាក់ដើម | % | ការប្រាក់ | % | |
| ការទូទាត់បំណុលសរុប | 213.51 | 247.09 | 190.99 | 77% | 56.1 | 23% | 16% |
| សងទៅពហុភាគី | 58.39 | 66.85 | 51.1 | 76% | 15.75 | 24% | 14% |
| សងទៅទ្វេភាគី | 155.12 | 180.24 | 139.89 | 78% | 40.35 | 22% | 16% |

### % ប្រភពនៃបំណុលសាធារណៈក្រៅប្រទេស




- ត្រឹមត្រីមាសទីពីរនៃឆ្នាំ2023 បំណុលសាធារណៈរបស់កម្ពុជាបានឈានដល់ចំនួន **10.71**ពាន់លានដុល្លារអាមេរិក ដែលបំណុលចំនួន **99.57**% ជាបំណុលសាធារណៈពីបរទេស
- ក្នុងឆ្នាំ **2024** រដ្ឋាភិបាលគ្រោងខ្ចីលុយ ចំនួន **1,700** លាន SDR ដែលត្រូវនឹង **2,233** លានដុល្លារអាមេរិក
- ទឹកប្រាក់ប្រមាណ **520**លានដុល្លារអាមេរិក ( ប្រមាណជា **23.6**% ) នៃ **2,233**លានដុល្លារអាមេរិក នឹងត្រូវបានប្រើប្រាស់សម្រាប់ទូទាត់បំណុល
- នៅត្រឹមចុងឆ្នាំ**2024** បំណុលសាធារណៈអាចនឹងកើនឡើងដល់ **12.9** ពាន់លានដុល្លារអាមេរិកស្មើនឹង **36**% នៃ ផ.ស.ស

ឯកតា លានដុល្លារសហរដ្ឋអាមរិក

| សេចក្តីបរិយាយ | ត្រឹមចុងឆ្នាំ 2023 | | ត្រឹមចុងឆ្នាំ 2024 | |
|---|---|---|---|---|
| | ចំនួនទឹកប្រាក់ | % នៃ ផ.ស.ស | ចំនួនទឹកប្រាក់ | % នៃ ផ.ស.ស |
| ផ.ស.ស សរុប | 32,189.42 | | 35,167.8 | |
| ស្តុកបំណុលសាធារណៈ | 11,241.95 | 34.92% | 12,955 | 36.84% |
| ការខ្ចីពីបរទេស (1) | | | 2,233 | |
| ទឹកប្រាក់ទូទាត់បំណុល (2) | | | 520 | |
| ទឹកប្រាក់បំណុលបន្ថែមលើស្តុកបំណុល (1)-(2) | | | 1,713 | |

ប្រភព៖ ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា ចេញផ្សាយលើកទី19, ទំព័រ 19, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ខែ សីហា 2023 និង 2) ខ្លឹមសារសង្ខេបប្រតិបត្តិ ស្តីពីសេចក្តីព្រាងច្បាប់ថវិកា ឆ្នាំ 2024

## មតិយោបល់

ការធានា និងការគ្រប់គ្រងបានដោយជោគជ័យលើបំណុលសាធារណៈគឺមានសារៈសំខាន់បំផុតចំពោះរដ្ឋាភិបាល ដើម្បីកាត់បន្ថយវត្តមាននៃរចនាសម្ព័ន្ធ និងយុទ្ធវិធីនៃបំណុលប្រកបដោយគ្រោះថ្នាក់ ព្រមទាំងទប់ស្កាត់ ចំពោះហានិភ័យនានាដល់អធិបតេយ្យភាពពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុល។ សារៈសំខាន់នៃតម្លាភាព និងគណនេយ្យភាពនៅក្នុងការគ្រប់គ្រងបំណុលសាធារណៈព្រមទាំងសុចរិតភាពនៃស្ថាប័នសាធារណៈដែលទទួលខុសត្រូវចំពោះកិច្ចការនេះ មិនអាចមិនយកចិត្តទុកដាក់បានឡើយ។ កត្តាចំបាច់ទាំងនេះ មិនត្រឹមតែការកាត់បន្ថយហានិភ័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់ការជំរុញទំនុកចិត្តសាធារណៈផងដែរ។ នៅក្នុងបរិបទនេះ សវនករខាងក្រៅប្រកបដោយសមត្ថភាពគប្បីចូលរួមក្នុងដំណើរការដើម្បីធានាសុចរិតភាពនៃការគ្រប់គ្រងបំណុល។ សកម្មភាពគ្រប់គ្រង និងចាត់ចែងបំណុលសាធារណៈគប្បីឆ្លងកាត់សវនកម្មខាងក្រៅជាប្រចាំឆ្នាំ ដើម្បីប្រកាន់ខ្ជាប់ខ្ជួននូវការអនុលោមទៅតាមស្តង់ដាដែលកំពុងមាន។ លទ្ធផល និងអនុសាសន៍ទទួលបានពីសវនកម្មនេះ គប្បីត្រូវរាយការណ៍ដល់ស្ថាប័នត្រួតពិនិត្យពាក់ព័ន្ធ។ បន្ថែមលើនេះ របាយការណ៍សំខាន់ៗពាក់ព័ន្ធនឹងសកម្មភាពគ្រប់គ្រងបំណុល គប្បីបង្ហាញផ្សាយដល់សាធារណជន។

## ប្រភពចំណូលថវិការដ្ឋ




- ក្នុងឆ្នាំ 2024 ចំណូលដែលបានមកពីប្រភពចំណូលសារពើពន្ធ មានរហូតដល់ 86% គិតជាទឹកប្រាក់ 6,999 លានដុល្លាអាមេរិក ដែលកើនឡើងចំនួន 9.3% ធៀបនឹងឆ្នាំ 2023
- ការកើនឡើងគួរកត់សម្គាល់នៃចំណូលដែលបានមកពីចំណូលមិនមែនសារពើពន្ធ គឺមានរហូតដល់ 29.5%
  - ផលចំណេញពីទ្រព្យសម្បត្តិរបស់រដ្ឋ កើន 219%៖ ចាប់ពី 42 លានដុល្លារអាមេរិកនៅឆ្នាំ2024 ដល់ 136 លានដុល្លារអាមេរិក នៅឆ្នាំ2024
  - ផលចំណេញពីការលក់ ការជួលទ្រព្យរបស់រដ្ឋ កើន 35% ពី 391 លានដុល្លារអាមេរិកនៅឆ្នាំ2023 ទៅ 531 លានដុល្លារអាមេរិក នៅឆ្នាំ2024
  - ចំណូលពីការផាកពិន័យ និងទណ្ឌកម្មផ្សេងៗធ្លាក់ចុះចំនួន 9%៖ ពី 17.5 លានអាមេរិកនៅឆ្នាំ2023 ទៅ 15.9 លានដុល្លារអាមេរិក នៅឆ្នាំ2024។

ឯកតា លានរៀល

| ប្រភេទនៃប្រភពចំណូលមិនមែនសារពើពន្ធ | ចំនួនទឹកប្រាក់ | | | | | | | ប្រែប្រួលជា % | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 | 2019 | 2020 | 2021 | 2022 | 2023 | 2024 |
| ផលធននៃទ្រព្យសម្បត្តិរដ្ឋ | 207,583.46 | 273,822.79 | 401,169.24 | 205,084.50 | 173,953.00 | 173,809.40 | 555,925.80 | 31.91 | 46.51 | -48.88 | -15.18 | -0.08 | 219.85 |
| ផលធននៃការលក់ ជួលទ្រព្យសម្បត្តិរដ្ឋនិងការផ្តល់សេវា | 1,845,869.13 | 2,291,834.75 | 1,246,303.45 | 1,470,910.20 | 1,326,046.30 | 1,593.326.10 | 2,160,153.90 | 24.16 | -45.62 | 18.02 | - 9.85 | 20.16 | 35.58 |
| ផលពីការពិន័យ និងដាក់ទណ្ឌកម្ម | 39,325.33 | 44,124.30 | 80,943.75 | 59,787.30 | 65,765.30 | 71,419.10 | 64,699.30 | 12.20 | 83.44 | -26.14 | 10.00 | 8.60 | -9.41 |
| ផលហិរញ្ញវត្ថុ | 180,797.50 | 169,962.51 | 139,951.25 | 120,007.00 | 173,328.00 | 211,638.40 | 296,631.00 | -5.99 | -17.66 | -14.25 | 44.43 | 22.10 | 40.16 |
| ផលផ្សេងៗ និងផលពិសេស | 33,735.37 | 94,603.81 | 50,706.46 | 39.00 | 40.40 | 6.00 | 6.00 | 180.51 | -46.40 | -99.92 | 3.59 | - 85.15 | 0.00 |

ប្រភព៖ ច្បាប់ថវិកាជាតិឆ្នាំ 2021 ដល់ 2024 ច្បាប់ទូទាត់ថវិកាជាតិ ឆ្នាំ 2018 ដល់ 2021

## ចំណូលពីពន្ធលើតម្លៃបន្ថែម( VAT ) និងពន្ធលើប្រាក់ចំណូលពីបុគ្គល(រូបវន្តបុគ្គល និងនីតិបុគ្គល )

### ភាពប្រែប្រួលនៃចំណូលបានមកពីអាករលើតម្លៃបន្ថែម VAT ( ឯកតា លានដុល្លាអាមេរិក )




- ចំណូលបានមកពីអាករលើតម្លៃបន្ថែម(VAT) ៖
  - 990 លានដុល្លារអាមេរិក ស្មើនឹង 49% នៃចំណូលពីពន្ធប្រយោល ដែលកើនចំនួន 6 ពិន្ទុភាគរយ បើធៀបនឹងឆ្នាំ2023
  - ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ ចំណូលពីVAT បានកើនឡើងជាមធ្យមចំនួន 15%
  - ការពង្រឹងការអនុវត្តការប្រមូលអាករលើតម្លៃបន្ថែម VAT អាចធ្វើឲ្យធ្លាក់ចុះនូវវិធាន ឬប្រព័ន្ធពន្ធដែលគាំទ្រក្រុមជនងាយរងគ្រោះ និងមានជីវភាពក្រីក្រ និងមិនបានលើកទឹកចិត្តដល់ សកម្មភាពពាណិជ្ជកម្មថ្មីៗ ឬមុខរបររកស៊ីខ្នាតតូច

ឯកតា លានរៀល

| សេចក្តីបរិយាយ | 2018 | | 2019 | | 2020 | | 2021 | | 2022 | | 2023 | | 2024 | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % |
| ពន្ធផ្ទាល់ | 4,059,155.00 | | 5,045,260.80 | | 5,779,410.11 | | 4,304,000.00 | | 5,481,000.00 | | 7,257,989.00 | | 8,957,173.00 | |
| ពន្ធលើប្រាក់ចំណូល(រូបវន្ត) | 162,108.99 | 3.99 | 142,285.15 | 2.82 | 120,007.32 | 2.08 | 144,000.00 | 3.35 | 86,000.00 | 1.57 | 45,000.00 | 0.62 | 45,000.00 | 0.50 |
| ពន្ធលើប្រាក់ចំណូល( នីតិបុគ្គល ) | 3,192,191.86 | 78.64 | 4,055,158.01 | 80.38 | 4,738,772.11 | 81.99 | 3,410,000.00 | 79.23 | 4,400,000.00 | 80.28 | 5,900,000.00 | 81.29 | 7,300,000.00 | 81.50 |
| ពន្ធលើប្រាក់បៀវត្ស | 704,854.14 | 17.36 | 847,817.64 | 16.80 | 920,630.68 | 15.93 | 750,000.00 | 17.43 | 995,000.00 | 18.15 | 1,312,989.00 | 18.09 | 1,608,173.00 | 17.95 |

ប្រភព ៖ ច្បាប់ថវិកាជាតិឆ្នាំ 2021 ដល់ 2024 ច្បាប់ទូរទាត់ថវិកាជាតិ 2018 - 2020

- ពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណេញ
  - ចំណូលពីពន្ធទាំងនេះដែលបង់ដោយនីតិបុគ្គល និងរូបវន្តបុគ្គល។ ថវិកាប្រមាណ 1,798 លានដុល្លាអាមេរិកដែលស្មើនឹង 81.50%នៃពន្ធផ្ទាល់ នេះ គ្រោងនឹងប្រមូលពីនីតិបុគ្គល ហើយបើធៀបនឹងឆ្នាំ2023 ចំនួននេះបានកើនឡើង 23%។ ហើយចំណូលពីពន្ធលើប្រាក់ចំណូល ដែលប្រមូលពីរូបវន្តបុគ្គលគ្រោងនឹងឈានដល់ចំនួន 11 លានដុល្លារអាមេរិក (0.50%) នៃពន្ធផ្ទាល់ ដែលដូចគ្នានឹងឆ្នាំ2023។
  - ចំណូលពីពន្ធលើប្រាក់បៀវត្សរ៍ មានកំណើនកម្រិតមធ្យមចំនួន 22% ពី 323 លានដុល្លាររអាមេរិកនៅឆ្នាំ2023 ទៅ 395 លានដុល្លាររអាមេរិក នៅឆ្នាំ2024។

### ការប្រែប្រួលជាភាគរយ % ធៀបនឹងពន្ធផ្ទាល់



## ចំណូលពីពន្ធលើផលិតផលថ្នាំជក់ គ្រឿងស្រវឹង និងភេសជ្ជមានជាតិស្ករ និងអាហារមានកម្រិតសារជាតិចិញ្ចឹមទាប

- ការតម្លើងពន្ធលើផលិតផលទាំងអស់នេះរំពឹងថានឹងធ្វើអោយមាននូវការផ្លាស់ប្តូរយ៉ាងវិជ្ជមានលើអាកប្បកិរិយា ការគិត និងការរស់នៅរបស់ប្រជាជន ចូលរួមកាត់បន្ថយនូវចំណាយរបស់រដ្ឋលើវិស័យថែទាំសុខភាព និងបង្កើននូវចំណូលរបស់ជាតិ
- ការប្រមូលចំណូលពីអាករពិសេសនេះមានលក្ខណៈជាបណ្តើរៗ ដែលមានកំណើនត្រឹមតែ 6% ប៉ុណ្ណោះសម្រាប់ឆ្នាំ2023 និង2024។ ស្របពេលដែលនៅឆ្នាំ2019 ចំណូលពីអាករពិសេសមានកំណើន30% បើធៀបនឹងឆ្នាំ2018
- ពន្ធអាករដែលបានមកពីផលិតផលទាំងអស់នេះមានការកើនឡើងដល់ 1,424 លានដុល្លារអាមេរិកក្នុងឆ្នាំ 2024 ក៏ដោយក៏នៅតែទាបជាងប្រមូលក្នុងឆ្នាំ2019 នៅមុនពេលមានការរាតត្បាតជំងឺកូវីដ19

### ការប្រែប្រួលនៃចំណូលដែលបានមកពីការយកពន្ធពិសេស ( ឯកតា លានដុល្លារអាមេរិក )




ឯកតា លានរៀល

| សេចក្តីបរិយាយ | ចំនួនទឹកប្រាក់ | | | | | | | ប្រែប្រួលជា % | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 | 2019 | 2020 | 2021 | 2022 | 2023 | 2024 |
| អាករពិសេស | 4,969,065.97 | 6,477,641.07 | 4,580,802.97 | 4,508,800.00 | 5,125,300.00 | 5,459,550.00 | 5,789,510.70 | 30.36 | - 29.28 | - 1.57 | 13.67 | 6.52 | 6.04 |

ប្រភពៈច្បាប់ថវិកាជាតិឆ្នាំ 2021 - 2024 និងច្បាប់ទូរទាត់ថវិកាជាតិឆ្នាំ 2018 - 2020

### មតិយោបល់

- រាជរដ្ឋាភិបាលគប្បីបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីធានានូវ យុត្តិធម៌ និងតម្លាភាពនៅក្នុងការប្រមូលចំណូល ដើម្បីជៀសវាងការបាត់បង់សក្តានុពលចំណូលថវិការដ្ឋ ។ ការពង្រឹង ការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមានស្រាប់ ដោយហ្មត់ចត់ និងដោយស្មើភាពគ្នាចំពោះអ្នកបង់ពន្ធគ្រប់រូប នឹងបង្កើនចំណូលថវិការដ្ឋ និងជំរុញឱ្យមានលក្ខខណ្ឌស្មើភាពគ្នាក្នុងការប្រកួតប្រជែង។
- យើងសូមលើកទឹកចិត្តដល់រាជរដ្ឋាភិបាលឱ្យបង្កើនពន្ធពិសេសទៅលើទំនិញជាក់លាក់ ជាពិសេសថ្នាំជក់ គ្រឿងស្រវឹង និងផលិតផលមានជាតិស្ករ។ នៅកម្ពុជា អត្រាពន្ធ លើបារី គ្រឿងស្រវឹង និងភេសជ្ជមានជាតិស្ករ គួរត្រូវបានបង្កើនដើម្បីទទួលបានចំណូលបន្ថែមទៀត និងដើម្បីកាត់បន្ថយការប្រើប្រាស់ និងកាត់បន្ថយឥទ្ធិពលប្រកបដោយគ្រោះថ្នាក់នៃផលិតផលទាំងនេះទៅលើសេវាថែទាំសុខភាព និងបន្ទុកសេដ្ឋកិច្ចរបស់រដ្ឋ និងប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋដែលកំពុងរស់នៅក្រោមបន្ទាត់ភាពក្រីក្រ។ បន្ថែមលើនេះ រាជរដ្ឋាភិបាលគប្បីធានាថា ក្រុមហ៊ុនគ្រឿងស្រវឹងអនុវត្តពេញលេញទៅតាមកាតព្វកិច្ចបង់ពន្ធជាធរមាន។
- ដើម្បីកាត់បន្ថយឥទ្ធិពលប្រកបដោយគ្រោះថ្នាក់របស់បារី និងគ្រឿងស្រវឹងទៅលើប្រជាពលរដ្ឋវ័យក្មេង រួមទាំងកុមារ រាជរដ្ឋាភិបាលចាំបាច់ត្រូវចេញប្រកាស សេចក្តីណែនាំ ឬអនុម័តច្បាប់ដែលបញ្ជាក់អំពី ការកំណត់អាយុសម្រាប់ការប្រើប្រាស់គ្រឿងស្រវឹង។ ការផ្សាយពាណិជ្ជកម្មបារី និងគ្រឿងស្រវឹងនៅតាមទីសាធារណៈគប្បីត្រូវបានហាមឃាត់ ដើម្បីកាត់បន្ថយការទទួលបាននូវព័ត៌មានទាំងនោះជាសាធារណៈពីសំណាក់សាធារណជនទូទៅ។
- បន្ថែមលើនេះ រាជរដ្ឋាភិបាលគប្បីពិចារណាពង្រីកវិសាលភាពនៃការអនុវត្តបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងពន្ធ ហើយបង្កើនអត្រាពន្ធទៅលើភេសជ្ជៈនាំចូលដែលមានជាតិស្ករ។ ផលិតផលដែលមានជាតិស្ករកាន់តែខ្ពស់គប្បីត្រូវបង់ពន្ធក្នុងអត្រាកាន់តែច្រើន។ រាជរដ្ឋាភិបាលក៏គប្បីគ្រប់គ្រងលើសារធាតុចិញ្ចឹមនៅក្នុងអាហារតម្លៃថ្លៃតែមានមានសារធាតុចិញ្ចឹមទាប ដែលមានឥទ្ធិពលអវិជ្ជមានលើកុមារនៅតាមសាលារៀន និងកុមារតូចៗផងដែរ។

## ចំណូលពីពន្ធលើអចលនទ្រព្យ

- នៅឆ្នាំ2024 គម្រោងប្រមូលបានពន្ធលើអចលនទ្រព្យបាន 50.32 លានដុល្លាអាមេរិកស្មើ 0.14% នៃ ផ.ស.ស ដែលកើនឡើងចំនួន 19% ធៀបនឹងឆ្នាំ2023

### ការប្រែប្រួលនៃចំណូលដែលបានមកពីការយកពន្ធលើអចលនទ្រព្យ និង ដីធ្លីមិនប្រើប្រាស់ (ឯកតា លានដុល្លារអាមេរិក)




ឯកតា លានរៀល

| សេចក្តីបរិយាយ | ចំនួនទឹកប្រាក់ | | | | | | | ប្រែប្រួលជា % | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 | 2019 | 2020 | 2021 | 2022 | 2023 | 2024 |
| ពន្ធលើអចលនទ្រព្យ | 134,016.59 | 161,581.20 | 153,964.87 | 102,153.00 | 143,123.40 | 171,797.90 | 204,565.40 | 20.57 | -4.71 | -33.65 | 40.11 | 20.03 | 19.07 |
| ពន្ធលើដីធ្លីមិនប្រើប្រាស់ | 17,719.02 | 25,757.72 | 20,703.42 | 4,094.00 | 13,694.40 | 17,705.20 | 22,004.00 | 45.17 | -19.62 | -80.23 | 234.50 | 29.29 | 24.28 |

ប្រភព៖ច្បាប់ថវិកាជាតិឆ្នាំ 2021 - 2024 និងច្បាប់ទូរទាត់ថវិកាជាតិឆ្នាំ 2018 - 2020

- ដីធ្លី មិនបានប្រើប្រាស់រំពឹងនឹងកើនឡើងចំនួន 24% ដែលអាចនឹងប្រមូលពន្ធបានរហូតដល់ចំនួន 5.4 លានដុល្លារអាមេរិក (ឆ្នាំ2022 ប្រមូលបាន 3.3 លានដុល្លារអាមេរិក និងឆ្នាំ2023 ប្រមូលបាន 4.4 លានដុល្លារអាមេរិក) ដែលស្មើនឹង 10.7% នៃចំណូលពីពន្ធលើអចលនទ្រព្យ។
- ការអនុវត្តនូវការយកពន្ធនេះគឺនៅមានកម្រិតនៅឡើយពោលគឺ ការអនុវត្តពន្ធនេះលើអចលនទ្រព្យមានទីតាំងនៅរាជធានី និងទីក្រុងធ្វើឲ្យមូលដ្ឋានជាប់ពន្ធរួចតូចស្របពេលដែលមានការកើនឡើងនូវការរីកចំរើនហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ប្រជុំជនផ្សេងៗផងដែរ។

### មតិយោបល់

ការបង្កើនចំណូលពីពន្ធលើអចលនទ្រព្យទៅដល់ 1% (ឬលើសពីនេះ) នៃ ផ.ស.ស នឹងផ្តល់ផលប្រយោជន៍ជាចំបងដល់កម្ពុជា។ យើងស្នើឱ្យរាជរដ្ឋាភិបាលពង្រីកមូលដ្ឋានជាប់ពន្ធ បង្កើនអត្រាដែលមានប្រសិទ្ធភាពក្នុងការយកទៅអនុវត្ត និងប្រើប្រាស់ការវាយតម្លៃនូវតម្លៃទីផ្សារដែលមានបច្ចុប្បន្នភាព។ លើសពីនេះ យើងស្នើឱ្យរាជរដ្ឋាភិបាលពង្រឹងការប្រមូលពន្ធលើអចលនទ្រព្យពីអ្នកបង់ពន្ធទាំងអស់ ដោយផ្អែកលើលិខិតបទដ្ឋានជាធរមាន។

## ពន្ធលើប្រេងឥន្ធនៈ



- ពន្ធលើប្រេងឥន្ធនៈគឺជាការចូលរួមចំណែកចំពោះការគាំទ្រដល់ការផ្តល់សេវាពីរាជរដ្ឋាភិបាលក្នុងការការកសាង ការថែទាំ ការជួសជុលផ្លូវថ្នល់ និងការដឹកជញ្ជូនសាធារណៈដូចដែលថវិកាជាតិកំណត់ដោយផ្ទាល់នៅខ្ទង់ចំណូលលេខអនុគណនី 71004 ដែលជាចំណាយបន្ថែមសម្រាប់ការកែលម្អ ការថែទាំ និងការស្តារផ្លូវ។
- នៅឆ្នាំ2024 រាជរដ្ឋាភិបាលគ្រោងនឹងទទួលចំណូលដែលបានពីពន្ធលើប្រេងឥន្ធនៈ ចំនួនប្រមាណ 96 លានដុល្លារអាមេរិក
- មានពន្ធបួនប្រភេទដែលអនុវត្តចំពោះប្រេងឥន្ធនៈ រួមមាន ពន្ធតម្លៃបន្ថែមVAT(10%) ពន្ធគយ (0.0847 ដុល្លារអាមេរិកក្នុងមួយលីត្រ) ពន្ធពិសេស (0.0669 ដុល្លារអាមេរិកក្នុងមួយលីត្រ) និងពន្ធបន្ថែម (0.0200 ដុល្លារអាមេរិកក្នុងមួយលីត្រ)

- ការកំណត់នូវតម្លៃប្រេងឥន្ធនៈដើរតួនាទីសំខាន់នៅក្នុងការធានាបាន និងធ្វើឲ្យល្អនូវកម្រិតជីវភាពរស់នៅ
- គោលនយោបាយសារពើពន្ធអាចមានឥទ្ធិពលលើតម្លៃប្រេងឥន្ធនៈក្នុងប្រទេស

### មតិយោបល់

ដើម្បីកាត់បន្ថយបន្ទុកនៃកំណើនតម្លៃឥន្ធនៈទៅលើអ្នកប្រើប្រាស់ និងធុរកិច្ចនានា រាជរដ្ឋាភិបាលគប្បីពិចារណាលើការកាត់បន្ថយជាយុទ្ធសាស្ត្រចំពោះពន្ធលើប្រេងឥន្ធនៈ។ ការធ្វើបែបនេះអាចពាក់ព័ន្ធនឹងការទម្លាក់អាករលើតម្លៃបន្ថែម (VAT) ទៅលើប្រេងឥន្ធនៈពី 10% មកនៅ 5% ព្រមទាំងការអនុវត្តកាត់បន្ថយកម្រិតសមស្របទៅលើពន្ធពាក់ព័ន្ធផ្សេងទៀត។ វិធានការបែបនេះនឹងទម្លាក់តម្លៃសរុបរបស់ប្រេងឥន្ធនៈ និងផលប៉ះពាល់របស់វាទៅលើទំនិញ សេវា ភស្តុភារ និងផលិតកម្មនៅក្នុងច្រវាក់តម្លៃផ្សេងៗ។ ដើម្បីបំពេញលើកង្វះចំណូលដែលទទួលបានជាសក្តានុពលពីពន្ធលើប្រេងឥន្ធនៈ រាជរដ្ឋាភិបាលអាចរិះរកប្រភពចំណូលផ្សេងទៀតដូចជា ការបង្កើនពន្ធលើថ្នាំជក់ គ្រឿងស្រវឹង ភេសជ្ជៈមានជាតិស្ករ និងអចលនទ្រព្យ ដូចការស្នើខាងលើ។

## ការលើកទឹកចិត្តផ្នែកពន្ធ និងការចំណាយ

- ជាយុទ្ធសាស្ត្រ ដើម្បីទាក់ទាញការវិនិយោគទុនបែបមូលធន និងជំរុញឱកាសការងារ។
- នៅប្រទេសកម្ពុជា កម្រិតដែលការលើកទឹកចិត្តផ្នែកពន្ធរួមចំណែកចំពោះការទាក់ទាញ FDI នៅតែមិនច្បាស់លាស់។
- ទោះបីជាមានការលើកទឹកចិត្តផ្នែកពន្ធក្តី ប្រទេសកម្ពុជា គឺជាទីកន្លែងទាក់ទាញសម្រាប់ការវិនិយោគរួចហើយ ដោយសារកត្តាមួយចំនួនរួមមាន ការទទួលបានកម្លាំងពលកម្មដែលមានប្រសិទ្ធភាពសក្តិសមនឹងតម្លៃ ការមានកិច្ចព្រមព្រៀងពាណិជ្ជកម្មផ្នែកខ្លះដូចជា EBA និង GSP និងការបន្ធូរបន្ថយនូវបទដ្ឋានគតិយុត្តិធូរស្រាល លើភាពជាម្ចាស់កម្មសិទ្ធិរបស់ក្រុមហ៊ុនបរទេស។

### មតិយោបល់

ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលស្នើរាជរដ្ឋាភិបាលបោះពុម្ពផ្សាយជាប្រចាំនូវព័ត៌មានទាក់ទងនឹងនឹងការវាយតម្លៃលើប្រសិទ្ធភាពនៃការលើកទឹកចិត្តផ្នែកពន្ធ ជាពិសេស ព័ត៌មានទាក់ទងនឹងការចំណាយតាមរយៈការអនុវត្តការលើកទឹកនេះ និងផលជះត្រឡប់នៃឥរិយាបទអ្នកវិនិយោគ។

## ការចំណាយសម្រាប់វិស័យអប់រំ សុខាភិបាល និងកិច្ចគាំពារសង្គមនៅក្រោមខ្ទង់ថវិកានៃក្រសួងពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងវិស័យអប់រំ សុខភាពសាធារណៈ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងកិច្ចគាំពារសង្គម។
- បើធៀប ផ.ស.ស ការវិភាជថវិកាទៅតាមក្រសួងសំខាន់ៗទាំង 3 ប្រែប្រួលបន្តិចបន្តួច។

ក្រសួងអប់រំ យុវជន និង កីឡា




- ក្រសួងអប់រំ យុវជន និងកីឡាទទួលបានថវិកាចំនួន 2.83% នៃ ផ.ស.ស ឬ 11.75% នៃថវិកាចំណាយថ្នាក់ជាតិ។
- ដូចមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ2019-2023 វិស័យអប់រំមានបំណងបង្កើនចំណែកថវិការបស់ខ្លួនរហូតដល់ 19.1% នៃថវិកាជាតិទាំងស្រុងនៅត្រឹមឆ្នាំ2023 ដែលស្មើនឹង 3.1% នៃ ផ.ស.ស។
- លើសពីនេះ ក្របខណ្ឌសកម្មភាពអប់រំឆ្នាំ2030 (The 2030 Education Framework for Action) ដែលកម្ពុជាជាហត្ថលេខី បានផ្តល់អនុសាសន៍ថា រាជរដ្ឋាភិបាលគប្បីវិភាជថវិកាចំនួនពី 4% ទៅ 6% នៃផ.ស.សរបស់ខ្លួន និង/ឬ 15% - 20% នៃការចំណាយសាធារណៈទៅដល់វិស័យអប់រំ។

- ថវិកាចំនួនសរុប 430 លានដុល្លារអាមេរិក វិភាជទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនោះ 410 លានដុល្លារអាមេរិកត្រូវវិភាជទៅកាន់រដ្ឋបាលក្រុង ស្រុក និងប្រហែល 20 លានដុល្លារអាមេរិកទៅកាន់រដ្ឋបាលរាជធានី ខេត្តនៅទូទាំងប្រទេសសម្រាប់អនុវត្តមុខងារអប់រំនៅថ្នាក់ក្រោមជាតិ។
- នៅក្នុងចំណោមក្រសួង និងស្ថាប័នទាំងអស់របស់រដ្ឋ ក្រសួងអប់រំ យុវជន និងកីឡា បានទទួលនូវថវិកាច្រើនជាងគេ ខណៈក្រសួងការពារជាតិទទួលបានច្រើនលំដាប់ទី2 ស្មើ 2% នៃ ផ.ស.ស។




## ក្រសួងសុខាភិបាល

- នៅឆ្នាំ 2024 ចំនួន 1.87% នៃ ផ.ស.ស បង្ហាញអំពីការធ្លាក់ចុះចំនួន 0.32 ពិន្ទុភាគរយធៀបឆ្នាំ 2023 ដែលស្មើនឹងចំនួន 2.19%
- ថវិកាចំនួន 52.25 លានដុល្លារអាមេរិកបានធ្លាក់ចុះក្នុងឆ្នាំ 2024 ខណៈពេលដែលនៅឆ្នាំ 2023 មានការធ្លាក់ចុះម្តងរួចមកហើយចំនួន 1.8 លានដុល្លារអាមេរិកធៀបជាមួយឆ្នាំ2022
- ការកាត់បន្ថយថវិកាសម្រាប់វិស័យសុខាភិបាលទំនងជាផ្ទុយពីទាំងនិន្នាការសេដ្ឋកិច្ច និងទាំងការប្តេជ្ញាដែលរដ្ឋាភិបាលបានប្រកាស។
- ថវិកាសម្រាប់វិស័យសុខាភិបាលឆ្នាំ2024 មានចំនួនត្រឹមតែ 656 លានដុល្លារអាមេរិក។ ថវិកាដែលគ្រោងទុកនៅក្នុងផែនការយុទ្ធសាស្រ្តវិស័យសុខាភិបាលឆ្នាំ2016-2020 គ្រោងចំណាយរហូតដល់ចំនួន 745 លានដុល្លារអាមេរិកមកដល់ឆ្នាំ2024 នេះ ថវិកាខ្ទង់ចំណាយសម្រាប់វិស័យនេះមិនទាន់សម្រេចបាននៅឡើយ។




## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា




- តួលេខចំនួន 1.12% នៃ ផ.ស.ស ក្នុងឆ្នាំ 2023 កើនដល់ 1.62% នៅឆ្នាំ2024 ហើយថវិកាក្រសួងនេះមានកំណើនចំនួន 2.7 ពិន្ទុភាគរយដោយកើនឡើងពី 4.01% នៅឆ្នាំ2023 ទៅ 6.71% នៅឆ្នាំ2024។
- បន្ទាប់ពីការទូរទាត់តម្លៃសម្រាប់អតិផរណា ក្នុងអត្រាអតិផរណា 2.5%  ថវិកាដែលវិភាជថវិកាសម្រាប់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានកំណើនចំនួន 55%។
- ក្នុងឆ្នាំ 2024 រាជរដ្ឋាភិបាលនឹងវិភាជថវិកាប្រហែល 569 លានដុល្លារអាមេរិក ស្របពេលដែលក្នុងឆ្នាំ 2023 មានចំនួនត្រឹមតែ 367 លានដុល្លាអាមេរិក។

ឯកតា លានរៀល

| សេចក្តីបរិយាយ | ចំនួនទឹកប្រាក់ឆ្នាំ 2023 | អតិផរណាឆ្នាំ 2024: 2.5% | ចំនួនទឹកប្រាក់ឆ្នាំ 2024 មុនដកអតិផរណា | ចំនួនទឹកប្រាក់ឆ្នាំ 2024 ក្រោយដកអតិផរណា | ចំនួនទឹកប្រាក់ប្រែប្រួលពិតប្រាកដជា % (2023-2024) |
|---|---|---|---|---|---|
| ក្រសួងសុខាភិបាល | 2,880,574.60 | 72,014.37 | 2,688,153.00 | 2,596,138.64 | -9.87 |
| ក្រសួងអប់រំ យុវជន និងកីឡា | 3,730,157.00 | 93,253.93 | 4,051,781.00 | 3,958,527.08 | 6.12 |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 1,468,855.00 | 36,721.38 | 2,314,645.00 | 2,277,923.63 | 55.08 |

ប្រភព ៖ច្បាប់ថវិកាជាតិឆ្នាំ 2018 - 2024

ឯកតា លានរៀល

| សេចក្តីបរិយាយ | ឆ្នាំ 2018 | | | ឆ្នាំ 2019 | | | ឆ្នាំ 2020 | | | ឆ្នាំ 2021 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនទឹកប្រាក់ | % នៃ ផ.ស.ស | % នៃការចំណាយថវិកាជាតិ | ចំនួនទឹកប្រាក់ | % នៃ ផ.ស.ស | % នៃការចំណាយថវិកាជាតិ | ចំនួនទឹកប្រាក់ | % នៃ ផ.ស.ស | % នៃការចំណាយថវិកាជាតិ | ចំនួនទឹកប្រាក់ | % នៃ ផ.ស.ស | % នៃការចំណាយថវិកាជាតិ |
| ផ.ស.ស ( GDP ) | 99,116,041.0 | | | 109,894,949.0 | | | 119,034,229.0 | | | 117,939,000.0 | | |
| សរុបរួមចំណាយថវិកាថ្នាក់ជាតិ | 23,428,298.0 | | | 25,765,028.0 | | | 31,095,855.0 | | | 30,491,336.0 | | |
| ក្រសួងសុខាភិបាល | 1,967,851.0 | 1.99 | 8.40 | 1,820,925.0 | 1.66 | 7.07 | 2,102,899.4 | 1.77 | 6.76 | 2,228,069.0 | 1.89 | 7.31 |
| ក្រសួងអប់រំ យុវជន និងកីឡា | 3,438,007.5 | 3.47 | 14.67 | 3,661,670.2 | 3.33 | 14.21 | 3,738,130.3 | 3.14 | 12.02 | 3,436,236.0 | 2.91 | 11.27 |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 890,826.4 | 0.90 | 3.80 | 1,007,390.9 | 0.92 | 3.91 | 1,142,664.4 | 0.96 | 3.67 | 1,301,249.0 | 1.1 | 4.3 |

ឯកតា លានរៀល

| សេចក្តីបរិយាយ | ឆ្នាំ 2022 | | | ឆ្នាំ 2023 | | | ឆ្នាំ 2024 | | | បម្រែបម្រួលពីឆ្នាំ 2023-2024 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនទឹកប្រាក់ | % នៃ ផ.ស.ស | % នៃការចំណាយថវិកាជាតិ | ចំនួនទឹកប្រាក់ | % នៃ ផ.ស.ស | % នៃការចំណាយថវិកាជាតិ | ចំនួនទឹកប្រាក់ | % នៃ ផ.ស.ស | % នៃការចំណាយថវិកាជាតិ | ចំនួនទឹកប្រាក់ | % នៃ ផ.ស.ស | % នៃការចំណាយថវិកាជាតិ |
| ផ.ស.ស ( GDP ) | 124,162,000.0 | | | 131,276,000.0 | | | 142,975,000.0 | | | | | |
| សរុបរួមចំណាយថវិកាថ្នាក់ជាតិ | 32,576,866.0 | | | 36,603,698.0 | | | 34,497,444.0 | | | | | |
| ក្រសួងសុខាភិបាល | 2,888,090.4 | 2.33 | 8.87 | 2,880,574.6 | 2.19 | 7.87 | 2,668,153.0 | 1.87 | 7.73 | -212,421.6 | -0.33 | -0.14 |
| ក្រសួងអប់រំ យុវជន និងកីឡា | 3,382,658.2 | 2.72 | 10.38 | 3,730,157.0 | 2.84 | 10.19 | 4,051,781.0 | 2.83 | 11.75 | 321,624.0 | -0.01 | 1.55 |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 1,426,095.0 | 1.15 | 4.38 | 1,468,855.0 | 1.12 | 4.01 | 2,314,645.0 | 1.62 | 6.71 | 845,790.0 | 0.5 | 2.70 |

ប្រភព ៖ ច្បាប់ថវិកាជាតិឆ្នាំ 2018 - 2024

- ក្រៅពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសំខាន់ៗមួយចំនួនទៀត ដើរតួនាទីសំខាន់ក្នុងការរៀបចំ និងអនុវត្តគោលនយោបាយកិច្ចគាំពារសង្គមនៅកម្ពុជា។ ក្នុងនោះរួមមាន ក្រសួងសុខាភិបាល ក្រសួងផែនការ ក្រសួងអប់រំយុវជន និងកីឡា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

## មតិយោបល់

- ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងចីរភាព រាជរដ្ឋាភិបាលគប្បីចាត់អាទិភាពលើការផ្តល់មូលនិធិដ៏ខ្លាំងក្លាដល់វិស័យសំខាន់ៗ នោះគឺ វិស័យអប់រំ សុខាភិបាល និងសង្គមកិច្ច។ ការចាត់អាទិភាពនេះពាក់ព័ន្ធនឹងការបង្កើនការវិភាជថវិកាទៅដល់វិស័យទាំងនេះ ស្របពេលតំណាលគ្នានេះ ផ្តោតការយកចិត្តទុកដាក់លើការពង្រឹងគុណភាពនៃការផ្តល់សេវា។ ជាមួយនឹងការវិភាជថវិកានៅមានកម្រិតទៅដល់វិស័យសុខាភិបាល រដ្ឋាភិបាលគប្បីលើកទឹកចិត្តចំពោះកិច្ចសហការរវាងប្រធានមណ្ឌលសុខភាព និងមេឃុំ/ចៅសង្កាត់ការកៀរគរធនធាន និងចាត់ចែងធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ជាពិសេសនៅតាមតំបន់ជនបទ គឺជាការចាំបាច់ ដើម្បីដោះស្រាយបញ្ហាប្រឈម នៅ តាមទីតាំងភូមិសាស្ត្រ និងធានានូវលទ្ធភាពប្រកបដោយសមធម៌ក្នុងការទទួលបានការអប់រំ ការថែទាំសុខភាព និងសេវាគាំទ្រសង្គមប្រកបដោយប្រសិទ្ធភាព។ កម្មវិធីកសាងសមត្ថភាព ដែលសង្កត់ធ្ងន់លើសុចរិតភាព គណនេយ្យភាព និងគុណតម្លៃ សីលធម៌គប្បីត្រូវបានបញ្ចូលទៅក្នុងគំនិតផ្តួចផ្តើមទាំងនេះ ដើម្បីជំរុញវប្បធម៌នៃអភិបាលកិច្ចប្រកបដោយក្រមសីលធម៌ និងការផ្តល់សេវាប្រកបដោយការទទួលខុសត្រូវ។ សង្កាត់ឱ្យធ្វើការងាររួមគ្នាទៅលើផែនការវិនិយោគឃុំសង្កាត់ ដើម្បីវិភាជថវិកា សម្រាប់ការគាំទ្រមណ្ឌលសុខភាពនៅក្នុងមូលដ្ឋាន ដើម្បីពង្រឹងសេវា ព្រមទាំងបរិក្ខារសុខភាព។

## សម្រាប់វិស័យអប់រំ

- រាជរដ្ឋាភិបាលកម្ពុជាគប្បីប្តេជ្ញាចិត្តវិភាជជាបណ្តើរៗនូវថវិកាចំនួន 20% នៃការចំណាយរបស់រដ្ឋាភិបាល ទៅដល់វិស័យអប់រំដូចការសន្យានៅឆ្នាំ2021។ ទន្ទឹមនឹងនេះ គប្បីខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយភាពខុសគ្នានៃគុណភាពរវាងសាលារៀនឯកជន និងសាលារៀនរដ្ឋនៅទូទាំងប្រទេស។ ការបង្កើនថវិកានេះគប្បីត្រូវបានវិនិយោគលើការពង្រឹងគុណភាពនៃការអប់រំ ( ទាំងគុណភាពនៃការរៀនសូត្រ និងគុណភាពនៃការបង្រៀន ) ជាពិសេស ការអប់រំមូលដ្ឋានរយៈពេលប្រាំបួនឆ្នាំ។ កុមារគប្បីទៅរៀននៅសាលារៀនល្អៗនោះគឺ “សាលារៀនគំរូ” នៅក្នុងទីតាំងដែលពួកគេអាចធ្វើដំណើរទៅដល់បាន ហេតុនេះ រាជរដ្ឋាភិបាលគប្បីវិនិយោគលើការគាំទ្រដល់សាលារៀននៅតាមទីជនបទ ដើម្បីឱ្យក្លាយទៅជា “សាលារៀនគំរូ”។
- រាជរដ្ឋាភិបាលត្រូវតែប្រកាន់ខ្ជាប់ខ្លួននូវការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការធានាថា កុមារទាំងអស់ទទួលបានការអប់រំមូលដ្ឋានរយៈពេលប្រាំបួនឆ្នាំជាមួយនឹងកិច្ចគាំទ្របន្ថែមសម្រាប់សិស្សានុសិស្សក្រីក្រ កុមារមានពិការភាព និងកុមារងាយរងគ្រោះ ជាពិសេស នៅក្នុងរយៈពេលក្រោយការរាតត្បាតជំងឺកូវីដ 19។
- វិភាជថវិកាមួយផ្នែកសម្រាប់ការជួសជុលសាលារៀន និងការបំពាក់ដល់សាលារៀននូវហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យាចាំបាច់ ដើម្បីបង្កើតបរិយាកាសរៀនសូត្រ ដែលកាន់តែមានមេត្រីភាព និងបរិយាកាសល្អសម្រាប់កុមារ។
- វិនិយោគកាន់តែច្រើនលើការបណ្តុះបណ្តាលគ្រូបង្រៀនដែលកំពុងបម្រើការងារ តាមរយៈការជំរុញការប្រើប្រាស់ប្រព័ន្ធ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ នៅកម្រិតសាលារៀន និងនាយកសាលារៀន មុនពេលឱ្យពួកគេទៅបម្រើការងារ និងពង្រឹងសមត្ថភាពរបស់គ្រូបង្រៀន និងនាយកសាលារៀនដែលមានស្រាប់ ដើម្បីឱ្យស្របទៅតាមស្តង់ដានៅសតវត្សទី21នេះ។
- សម្របសម្រួលភាពជាដៃគូប្រកបដោយបរិយាបន្ន និងការកៀរគរធនធានពីអ្នកពាក់ព័ន្ធនានា រួមទាំងអង្គការសង្គមស៊ីវិល វិស័យឯកជន និងសហគមន៍ ដើម្បីអនុវត្តយុទ្ធសាស្ត្រ និងផែនការចាំបាច់ សម្រាប់ការពង្រឹងគុណភាព និងការវិនិយោគលើវិស័យអប់រំ។
- លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការផ្ទេរមុខងារ ដើម្បីធានានូវការយល់ដឹងក្នុងចំណោម សហគមន៍ និងធានានូវតម្លាភាពក្នុងការគ្រប់គ្រងធនធាន។ ក្នុងអំឡុងពេលអន្តរកាលនេះ អ្នកពាក់ព័ន្ធ ឬស្ថាប័នពាក់ព័ន្ធគប្បីផ្តល់កិច្ចគាំទ្របន្ថែមទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងទិដ្ឋភាពបច្ចេកទេសនៃមុខងារទាំងនេះ។

## សម្រាប់កិច្ចគាំពារសង្គម

- រាជរដ្ឋាភិបាលគប្បីពង្រីកវិសាលភាព និងសមធម៌នៃគោលនយោបាយកិច្ចគាំពារសង្គម ដើម្បីគ្របដណ្តប់ទៅដល់ក្រុមងាយរងគ្រោះ ដូចជាអ្នកទាំងឡាយដែលធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ មនុស្សចាស់ ជនមានពិការភាព និងសហគមន៍ជនជាតិដើម។ គោលនយោបាយទាំងនេះគប្បីចាត់អាទិភាពលើសន្តិសុខប្រាក់ចំណូល សម្រាប់យុវជន ពលករចំណាកស្រុក និងជនអត់ការងារធ្វើ។ បន្ថែមលើនេះ រាជរដ្ឋាភិបាលគប្បីពង្រីកការគ្របដណ្តប់នៃកិច្ចគាំពារសង្គមទៅដល់សហគ្រាសមីក្រូខ្នាតតូច និងមធ្យម ( MSMEs ) និងកសិករម្ចាស់ចម្ការតូចៗនៅក្នុងវិស័យនានា ដូចជា ចម្ការកៅស៊ូ អំពៅ ចេក និងវិស័យកសិកម្មផ្សេងទៀត។ ការតម្រូវឲ្យបានទាំងស្រុងអំពីការ ការពង្រឹងការអនុវត្តកាតព្វកិច្ចរបស់ម្ចាស់អាជីវកម្ម និងនិយោជក ចំពោះការផ្តល់នូវរបបសន្តិសុខសង្គមដល់និយោជិត តាមរយៈការដាក់ចេញនូវការអនុវត្តច្បាប់កាន់តែម៉ឺងម៉ាត់ពីសំណាក់ មន្ត្រី ប.ស.ស និងរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងធានាបានថាបុគ្គលទាំងនេះអាចទទួលបានអត្ថប្រយោជន៍ពីវិធានការកិច្ចគាំពារសង្គម ។
- តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជរដ្ឋាភិបាលកម្ពុជាគប្បីពិចារណាវិភាជ 5.1% នៃ ផ.ស.សទៅដល់វិស័យគាំពារសង្គម ដូចអនុសាសន៍សកលសម្រាប់ប្រទេសមានចំណូលមធ្យមកម្រិតទាប។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គប្បីវិភាជថវិកាច្រើនបន្ថែមទៀតទៅដល់ប្រព័ន្ធសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសាររបស់ពួកគេ ដើម្បីពង្រឹងសុខុមាលភាព និងសេដ្ឋកិច្ចរបស់អតីតយុទ្ធជន មនុស្សចាស់ និងជនមានពិការភាព។ បន្ថែមលើនេះ យើងស្នើឱ្យក្រសួងពិនិត្យឡើងវិញលើការអនុវត្តគោលនយោបាយសោធនិវត្តន៍ សម្រាប់មនុស្សចាស់ និងការបង្កើតមណ្ឌលថែទាំ ដើម្បីគាំទ្រ និងលើកកម្ពស់សិទ្ធិរបស់មនុស្សចាស់នៅកម្ពុជា។
- ក្រុមប្រឹក្សាជាតិគាំពារសង្គម និងបេឡាជាតិគាំពារសង្គម គប្បីបង្កើនការវិភាជថវិកាទៅដល់កញ្ចប់ថែទាំសុខភាព សម្រាប់អ្នកមានបណ្ណ ប.ស.ស ដើម្បីអាចពង្រឹងគុណភាព និងប្រសិទ្ធភាពនៃសេវាថែទាំសុខភាព អនុញ្ញាតឱ្យមានការធ្វើរោគវិនិច្ឆ័យតាំងពីដំបូង និងការបង្ការ ព្រមទាំងបង្កើនទំនុកចិត្ត និងការទទួលស្គាល់ជាសាធារណៈ នៅក្នុងអំឡុងពេលនៃការចូលសម្រាកនៅមន្ទីរពេទ្យ ដោយសារគ្រោះថ្នាក់ការងារ ការពិនិត្យសុខភាព និងការព្យាបាល។

- ក្រុមប្រឹក្សាជាតិគាំពារសង្គម និងបេឡាជាតិគាំពារសង្គម គប្បីពង្រីកការគ្របដណ្ដប់ និងតាវកាលិកស្មើគ្នាពីកម្មវិធីសន្តិសុខសង្គម សម្រាប់កសិករខ្នាតតូច អ្នកបម្រើការងារសេវាកម្សាន្ត អ្នកធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ សហគមន៍នេសាទ និងអ្នកធ្វើការងារជាជនជាតិដើមជាដើម តាមរយៈការអនុវត្តសាកល្បងលើការរួមវិភាគទាន និងកម្រៃរួមវិភាគទានបដិភាគរបស់រាជរដ្ឋាភិបាល ដើម្បីធានានូវនិរន្តរភាព និងបរិយាបន្ននៃគោលនយោបាយ និងកម្មវិធីកិច្ចគាំពារសង្គម។
- ការកំណត់ដោយច្បាប់ឱ្យបញ្ចេញរបាយការណ៍ហិរញ្ញវត្ថុ និងសវនកម្មរបស់បេឡាជាតិគាំពារសង្គម និងក្រុមប្រឹក្សាជាតិគាំពារសង្គម ទៅដល់សាធារណជន អ្នកស្រាវជ្រាវ និង សង្គមស៊ីវិលដើម្បីធានានូវតម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រង ការចំណាយ និងការបែងចែកមូលនិធិឡើងវិញ។

## ការអនុវត្តថវិកា នៃអនុគណនី 62028 សម្រាប់ជំនួយសង្គមទៅដល់ប្រជាពលរដ្ឋ

- រាជរដ្ឋាភិបាលបានចាត់ប្រភេទនៃការចំណាយជាតិជាបួនប្រភេទ៖ 1) មធ្យោបាយនិងសេវា 2) បន្ទុកហិរញ្ញវត្ថុ 3) អន្តរាគមន៍សាធារណៈ និង 4) ការចំណាយផ្សេងទៀត។
- ក្នុងឆ្នាំ 2023 ថវិកាប្រមាណ 29% នៃ 5,126 លានដុល្លារអាមេរិកនៃចំណាយចរន្ត គឺចាត់ជាប្រភេទចំណាយអន្តរាគមន៍សាធារណៈ។ គណនីគោល 6202 ត្រូវបានកំណត់ជាចំណាយជំនួយសង្គមសម្រាប់ប្រជាពលរដ្ឋមានចំនួន 21% នៃចំណាយអន្តរាគមន៍សាធារណៈ។ នៅក្នុងគណនីគោលនេះ អនុគណនេយ្យ 62028 ដែលត្រូវបានកំណត់ជា "កិច្ចគាំទ្រផ្សេងទៀត" បានទទួលថវិកាប្រមាណ 163 លានដុល្លារអាមេរិក ដែលស្មើនឹង 52% នៃគណនេយ្យគោល6202។
- ថវិកាចំនួន 163 លានដុល្លារសហរដ្ឋអាមេរិកនេះបានបញ្ចូលទៅកាន់អនុគណនីនេះ ត្រូវបានបែងចែកក្នុងចំណោមក្រសួង ឬស្ថាប័នរដ្ឋរបស់រាជរដ្ឋាភិបាលនៅថ្នាក់កណ្ដាល ដែលក្រសួងនិងស្ថាប័នមួយចំនួនមិនទទួលបានការកំណត់ដោយច្បាប់អំពីកាតព្វកិច្ចអនុវត្តកម្មវិធីគាំពារសង្គម ដូចជា៖
    - ទីស្ដីការគណៈរដ្ឋមន្ត្រីទទួលបានថវិកា 13.13%
    - រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលទទួលបានថវិកា 1.60%
    - ហើយព្រឹទ្ធសភាទទួលបានថវិកា 0.64%

ឯកតា លានរៀល

| ការចំណាយសរុបដោយក្រសួងថ្នាក់កណ្ដាល ឬ ស្ថាប័នជាតិ ឆ្នាំ 2023 លើអនុគណនីចំណាយជំនួយផ្សេងៗ ដល់ប្រជាពលរដ្ឋ (62028) | ចំនួនទឹកប្រាក់ 624,371.10 | % |
|---|---|---|
| ព្រឹទ្ធសភា | 4,000.00 | 0.64 |
| ទីស្ដីការគណៈរដ្ឋមន្ត្រី | 82,000.00 | 13.13 |
| រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | 10,000.00 | 1.60 |
| ក្រសួងមហាផ្ទៃរដ្ឋបាលទូទៅ | 1,160.00 | 0.19 |
| ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | 2,300.00 | 0.37 |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 120.00 | 0.02 |
| ក្រសួងព័ត៌មាន | 250.00 | 0.04 |
| ក្រសួងសុខាភិបាល | 516,000.00 | 82.64 |
| ក្រសួងអប់រំ យុវជន និងកីឡា | 2,804.00 | 0.45 |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 497.00 | 0.08 |
| ក្រសួងបរិស្ថាន | 730.00 | 0.12 |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 1,900.00 | 0.30 |
| ក្រសួងយុត្តិធម៌ | 2,600.00 | 0.42 |
| តុលាការកំពូល | 10.00 | 0.00 |

ប្រភព ៖ចំណូល ចំណាយថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ 2023 ដោយអគ្គនាយកដ្ឋានថវិកា

## មតិយោបល់

វាមានសារៈសំខាន់ណាស់សម្រាប់រដ្ឋាភិបាលក្នុងការធានាឱ្យមានការប្រើប្រាស់ថវិកាប្រកបដោយតម្លាភាព និងគណនេយ្យភាព។ អង្គការសង្គមស៊ីវិល (CSOs) សូមកោតសរសើរចំពោះគំនិតផ្តួចផ្តើមដ៏ល្អប្រសើររបស់រដ្ឋាភិបាលក្នុងការជំរុញការវិនិយោគសាធារណៈក្នុងវិស័យសង្គម។ ទោះជាយ៉ាងណាក៏ដោយ វាជាការចាំបាច់ក្នុងការធានាទាំងប្រសិទ្ធភាព និងគណនេយ្យភាពនៃការអនុវត្តថវិកា។ លើសពីនេះទៀត វាជាការចាំបាច់សម្រាប់ក្រសួង ឬស្ថាប័នជាកាតព្វកិច្ចក្នុងការគ្រប់គ្រងថវិកានេះដោយផ្ទាល់។ នេះមិនត្រឹមតែធ្វើអោយប្រសើរឡើងនូវគណនេយ្យភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអនុញ្ញាតឱ្យរដ្ឋាភិបាលកាត់បន្ថយនូវការចំណាយប្រតិបត្តិការដែលទាក់ទងនឹងការអនុវត្តថវិកាដោយក្រសួង ឬស្ថាប័នការពារសង្គមដែលមិនពាក់ព័ន្ធ។

## ស្ថាប័នត្រួតពិនិត្យ

ឯកតា លានរៀល

| សេចក្តីបរិយាយ | ចំនួនទឹកប្រាក់ 2019 | % | 2020 | % | 2021 | % | 2022 | % | 2023 | % | 2024 | % | ប្រែប្រួលជា % 2020 | 2021 | 2022 | 2023 | 2024 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សរុបចំណាយថវិកាថ្នាក់ជាតិ | 25,765,028.0 | % | 31,095.855.0 | % | 30,491,336.0 | % | 32,576,866.0 | % | 36,603,698.0 | % | 34,497,444.0 | % | | | | | |
| រដ្ឋសភា | 183,783.0 | 0.71% | 193,937.0 | 0.62% | 162,699.0 | 0.53% | 200,586.0 | 0.62% | 211,120.0 | 0.58% | 219,313.0 | 0.64% | 5.52% | -16.11% | 23.29% | 5.25% | 3.88% |
| ព្រឹទ្ធសភា | 87,233.0 | 0.34% | 87,309.0 | 0.28% | 76,052.0 | 0.25% | 69,866.0 | 0.21% | 74,021.0 | 0.20% | 86,003.0 | 0.25% | 0.09% | -12.89% | -8.13% | 5.95% | 16.19% |
| អជ្ញាធរសវនកម្មជាតិ | 14,905.0 | 0.06% | 14,986.0 | 0.05% | 12,948.0 | 0.04% | 12,310.0 | 0.04% | 13,837.0 | 0.04% | 15,313.0 | 0.04% | 0.54% | -13.60% | -4.93% | 12.40% | 10.67% |
| ស្ថាប័នប្រយុទ្ធប្រឆាំងអំពើពុករលួយ | 46,536.4 | 0.18% | 50,815.0 | 0.16% | 42,549.0 | 0.14% | 41.872.0 | 0.13% | 48,442.0 | 0.13% | 52,549.0 | 0.15% | 9.19% | -16.27% | -1.59% | 15.69% | 8.48% |

ប្រភព:ច្បាប់ថវិកាជាតិឆ្នាំ2019 ដល់ 2024

- អង្គភាពត្រួតពិនិត្យ រួមមាន អង្គនីតិប្បញ្ញត្តិទាំងពីរ និងស្ថាប័ន/អាជ្ញាធរសវនកម្មជាតិ ព្រមទាំងស្ថាប័នប្រយុទ្ធប្រឆាំងអំពើពុករលួយ ទទួលបានអាណត្តិក្នុងការត្រួតពិនិត្យ និងធានាតម្លាភាព និងគណនេយ្យភាពនៅក្នុងការប្រើប្រាស់ថវិការដ្ឋ។
- ការអង្កេតអំពីថវិកាបើកចំហ (Open Budget Survey) ដែលធ្វើឡើង ដោយអង្គការភាពជាដៃគូថវិកាអន្តរជាតិ (IBP) បានវាយតម្លៃអំពីការត្រួតពិនិត្យរបស់កម្ពុជានៅខ្សោយនៅឡើយ។ នៅឆ្នាំ2021 កម្ពុជាបានទទួលពិន្ទុតែ 41/100 ប៉ុណ្ណោះ ទៅលើការត្រួតពិនិត្យថវិកា។ លទ្ធផលនៃការអង្កេតនេះបានបង្ហាញថា អង្គនីតិប្បញ្ញត្តិ និងស្ថាប័នសវនកម្មកំពូលរបស់កម្ពុជាធ្វើការត្រួតពិនិត្យបន្តិចបន្តួច នៅគ្រប់ដំណាក់កាលនៃដំណើរការថវិកា។
- ការធានាបានថា អង្គនីតិប្បញ្ញត្តិអាចទទួលបានធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានភស្តុភារដែលចាំបាច់សម្រាប់ការប្រតិបត្តិមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព គឺជាការចាំបាច់។ ថវិកាសម្រាប់អង្គនីតិប្បញ្ញត្តិត្រូវបានការធានានៅក្នុងរដ្ឋធម្មនុញ្ញ ប៉ុន្តែគ្មានការបញ្ជាក់អំពីចំនួនអប្បបរមាឡើយ។ ថវិកាសម្រាប់អង្គនីតិប្បញ្ញត្តិត្រូវបានបញ្ចូលនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ដែលគេហៅជាទូទៅថាថវិកាជាតិប្រចាំឆ្នាំ។
- ថវិកាជាតិដែលត្រូវបានវិភាជដល់រដ្ឋសភាជាតិនៅតែមិនប្រែប្រួលអស់រយៈពេលជាច្រើនឆ្នាំហើយ ដែលគិតជាភាគរយមានចំនួនជាមធ្យម 0.6% នៃចំណាយថ្នាក់ជាតិ ពីឆ្នាំ2019 ដល់ឆ្នាំ2024។ ទោះជាយ៉ាងណាក្តី ទំហំថវិកាបានធ្លាក់ចុះ 3.88% នៅឆ្នាំ2023 និង 5.22% នៅឆ្នាំ2024។
- ចំពោះអជ្ញាធរសវនកម្មជាតិទិន្នន័យបង្ហាញថា ចំណែកនៃថវិកានេះតិចជាងចំណែកថវិកានៃស្ថាប័នប្រឆាំងអំពើពុករលួយប្រហែលបីដង។ អាជ្ញាធរនេះបានទទួលថវិកាចំនួនត្រឹមតែ 0.06% ទៅ 0.04% ប៉ុណ្ណោះនៃថវិកាចំណាយថ្នាក់ជាតិពីឆ្នាំ2019 ទៅ 2024។ ទំហំថវិកាសម្រាប់អាជ្ញាធរនេះក្នុងឆ្នាំ2024 កើនឡើងចំនួន 10% ដែលឈានដល់ទំហំទឹកប្រាក់ 3.7 លានដុល្លារអាមេរិក។

## មតិយោបល់

- អង្គនីតិប្បញ្ញត្តិដើរតួនាទីសំខាន់នៅក្នុងការត្រួតពិនិត្យ និងផ្តល់ការអនុញ្ញាតចំពោះចំណាយសាធារណៈ និងការបង្កើនចំណូល។ ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលសូមផ្តល់មតិយោបល់អំពីការចូលរួមកាន់តែខ្លាំងក្លា និងសកម្មរបស់រដ្ឋសភា នៅក្នុងដំណើរការដ៏ពេញលេញនៃវដ្តថវិការដ្ឋ។ មុខងារត្រួតពិនិត្យគប្បីត្រូវបានអនុវត្តនៅគ្រប់ដំណាក់កាលដំណើរការរៀបចំថវិកាទាំងមូល ចាប់តាំងពីការរៀបចំ រហូតដល់កិច្ចប្រតិបត្តិការ និងការពិនិត្យតាមដានថវិកា ជាជាងតែក្នុងអំឡុងពេលដំណាក់កាលសវនកម្មប៉ុណ្ណោះ។
- ដើម្បីគាំទ្រប្រកបដោយប្រសិទ្ធភាពដល់រដ្ឋសភា នៅក្នុងការធ្វើសេចក្តីសម្រេចដោយផ្អែកលើព័ត៌មាន និងទិន្នន័យច្បាស់លាស់ ស្ថាប័ននីតិប្បញ្ញត្តិគប្បីបង្កើតការិយាល័យស្រាវជ្រាវថវិកា ទាំងនៅក្នុងរដ្ឋសភា និងព្រឹទ្ធសភា និងវិភាជថវិកាគ្រប់គ្រាន់ដើម្បីឱ្យការិយាល័យនេះបំពេញមុខងារប្រកបដោយប្រសិទ្ធភាព។

## ការប្រើប្រាស់កម្ចីបរទេសទៅលើការវិនិយោគសាធារណៈសំខាន់ៗ

### % ភាគរយនៃការវិនិយោគសាធារណៈ និង កម្ចីបរទេសដោយក្រសួង




- ថវិកាវិនិយោគសាធារណៈពីហិរញ្ញប្បទានក្នុងស្រុកនៅឆ្នាំ2024 បានថយចុះចំនួន 39.1%

នៅឆ្នាំ 2024 រាជរដ្ឋាភិបាលមានផែនការចំណាយថវិកា 1.527លានដុល្លារអាមេរិក ទៅលើគម្រោងវិនិយោគសាធារណៈ ដោយកៀរគរប្រភពថវិកាពីដៃគូខាងក្រៅនៅក្នុងទម្រង់ជាកម្ចី។ ក្រសួងចំបងៗទទួលបានថវិការួមមាន៖

- ក្រសួងសាធារណការ និងដឹកជញ្ជូន 34.29%
- ក្រសួងអភិវឌ្ឍន៍ជនបទ (15.01%)
- ក្រសួងធនធានរ៉ែ និងថាមពល 9.04%
- ក្រសួងធនធានទឹក និង ឧតុនិយម 11.13%
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ 5.30%
- ក្រសួងសុខាភិបាល 5.96%
- ក្រសួងអប់រំយុវជន និងកីឡា 3.8%
- ក្រសួងមហាផ្ទៃ 0.85%

### ការប្រែប្រួលនៃការវិនិយោគសាធារណៈនៅក្នុងក្រសួងសំខាន់ៗចំនួន 2



## តម្លាភាព និងគណនេយ្យភាពថវិកា



- ក្នុងភាពជាតំណាងរបស់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលធ្វើសេចក្តីសម្រេចចិត្តផ្នែកគោលនយោបាយសំខាន់ៗ ពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យរបស់ជាតិ និងបំណុលសាធារណៈ។ រាជរដ្ឋាភិបាលមានកាតព្វកិច្ចចំពោះប្រជាពលរដ្ឋរបស់ខ្លួនក្នុងការបំពេញភារកិច្ចប្រកបដោយគណនេយ្យភាព ដោយធានានូវការគ្រប់គ្រងធនធានទាំងនោះប្រកបដោយប្រសិទ្ធភាព និងទប់ស្កាត់ការកើតឡើងវិបត្តិដែលមិនអាចរំពឹងទុកមុន ពាក់ព័ន្ធនឹងបំណុល និងភាពរិចរឹលនៃធនធានធម្មជាតិ។

- ដើម្បីជំរុញទំនុកចិត្តជាសាធារណៈ និងគណនេយ្យភាពនៅក្នុងការគ្រប់គ្រងថវិកា និងធនធានរបស់រដ្ឋ រាជរដ្ឋាភិបាលត្រូវតែប្រកាន់ខ្ជាប់ខ្លួនទៅតាមគោលការណ៍មូលដ្ឋានដែលមិនអាចខ្វះបាន មានដូចជា ការធានានូវការផ្សព្វផ្សាយក្នុងរយៈរយៈពេលសមស្របនូវឯកសារពាក់ព័ន្ធនឹងថវិកា និងការឲ្យមានការចូលរួមពីភាគីពាក់ព័ន្ធក្នុងការពិគ្រោះយោបល់ក្នុងដំណើរការរៀបចំ អនុវត្ត តាមដានវាយតម្លៃថវិកា។

### មតិយោបល់

ដើម្បីលើកកម្ពស់តម្លាភាព និងបរិយាបន្នកាន់តែខ្លាំងនៅក្នុងដំណើរការរៀបចំថវិកា រាជរដ្ឋាភិបាលគប្បីពិចារណាបង្កើតថ្នាលអនឡាញ ដែលសម្របសម្រួលការប្រមូល និងការបញ្ចូលយោបល់សាធារណៈទៅក្នុងការរៀបចំគោលនយោបាយសារពើពន្ធ និងការរៀបចំថវិកា។

## ការចំណាយមិនបានគ្រោងទុក (ថវិកាបម្រុង)

- ថវិកាចំណាយមិនបានគ្រោងទុក (ថវិកាបម្រុង) ត្រូវបានព្យាករណ៍ថានឹងកើនឡើងដល់ 603.57 លានដុល្លារអាមេរិក ឬ 7.11% នៃចំណាយថ្នាក់ជាតិសរុប ធៀបនឹងឆ្នាំ 2023 គឺកើនឡើងក្នុងទំហំថវិកាដល់ទៅ 43%។
- នៅឆ្នាំ2020 និង 2021 ការចំណាយនេះគ្រោងក្នុងទំហំថវិកាកម្រិតមធ្យម ដែលមានចំនួន 2.70% និង 2.29% ។ ទោះបីជាយ៉ាងណាក្តី នៅក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ ការចំណាយនេះបានកើនឡើងទ្វេដង ពោលគឺការចំណាយនេះឈានដល់ 4.97% នៅឆ្នាំ2022 ហើយកើនដល់ 4.68% ក្នុងឆ្នាំ 2023 និងបន្តកើនដល់ 7.11% ក្នុងឆ្នាំ 2024។
- រាជរដ្ឋាភិបាលមានភាពចាំបាច់ក្នុងការអនុលោមទៅតាមលក្ខខណ្ឌសំខាន់ៗ ឲ្យបានម៉ឺងម៉ាត់ និងធានាថាថវិកានេះស្ថិតក្រោមការគ្រប់គ្រង និងប្រើប្រាស់ត្រឹមត្រូវស្របតាមនីតិវិធីហិរញ្ញវត្ថុ។

### បម្រែបម្រួលថវិកាចំណាយមិនបានគ្រោងទុកជា %




ឯកតា លានរៀល

| សេចក្តីបរិយាយ | ឆ្នាំ 2018 | | ឆ្នាំ 2019 | | ឆ្នាំ 2020 | | ឆ្នាំ 2021 | |
|---|---|---|---|---|---|---|---|---|
| | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % |
| សរុបចំណាយថ្នាក់ជាតិ | 23,428,298.00 | | 25,765,028.00 | | 31,095,855.00 | | 30,491,336.00 | |
| ចំណាយមិនទាន់បែងចែកមានមុខសញ្ញា | 4,289,435.00 | 18.31 | 5,006,459.00 | 19.43 | 8,592,575.00 | 27.63 | 10,322,966.00 | 33.86 |
| ចំណាយមិនបានគ្រោងទុក | N/A | N/A | 1,069,010.00 | 4.15 | 838,884.00 | 2.70 | 697,000.00 | 2.29 |

| សេចក្តីបរិយាយ | ឆ្នាំ 2022 | | ឆ្នាំ 2023 | | ឆ្នាំ 2024 | | ប្រែប្រួលក្នុង 2023-2024 | |
|---|---|---|---|---|---|---|---|---|
| | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % |
| សរុបចំណាយថ្នាក់ជាតិ | 32,576,866.00 | | 36,603,698.00 | | 34,497,444.00 | | -2,106,254.00 | -5.75 |
| ចំណាយមិនទាន់បែងចែកមានមុខសញ្ញា | 11,591,345.00 | 35.58 | 11,409,580.40 | 31.17 | 8,335,304.70 | 24.16 | -3,074,275.70 | -26.94 |
| ចំណាយមិនបានគ្រោងទុក | 1,618,264.00 | 4.97 | 1,713,847.00 | 4.68 | 2,454,267.00 | 7.11 | 740,420.00 | 43.20 |

ប្រភព ៖ ច្បាប់ថវិកាជាតិ ឆ្នាំ 2018 ដល់ 2024

## មតិយោបល់

- ប្រទេសកម្ពុជាប្រឈមមុខនឹងឱនភាពថវិកាប្រចាំឆ្នាំជាបន្តបន្ទាប់ ដែលធ្វើឱ្យរាជរដ្ឋាភិបាលចាំបាច់ត្រូវកាត់បន្ថយការចំណាយមិនបានគ្រោងទុកនេះឱ្យនៅត្រឹមមិនលើសពី 3% ជារៀងរាល់ឆ្នាំ។ ការកាត់បន្ថយនេះ គឺជាការចាំបាច់ដើម្បីវិភាជធនធានកាន់តែច្រើនទៅដល់វិស័យសំខាន់ៗ ដូចជាវិស័យសុខាភិបាល អប់រំ និងកិច្ចគាំពារសង្គម។
- ដើម្បីសម្រេចបានគោលដៅនេះ រាជរដ្ឋាភិបាល ចាំបាច់ប្រកាន់ខ្ជាប់ខ្ជួននូវវិធានការនៃអនុលោមភាពស្របតាមគោលការណ៍ និងគោលនយោបាយ ។ ការប្រកាន់ខ្ជាប់ខ្ជួននេះរួមមានការអនុវត្តម៉ឺងម៉ាត់នូវគោលនយោបាយពាក់ព័ន្ធ ដូចជា គោលនយោបាយហិរញ្ញវត្ថុ និងលទ្ធកម្មសាធារណៈ ដើម្បីទប់ស្កាត់ភាពមិនប្រក្រតី និងអំពើពុករលួយ។ ការការពារសុចរិតភាពនៃថវិកានេះត្រូវការសវនកម្មឯករាជ្យ និងការត្រួតពិនិត្យទាំងស្រុងពីសំណាក់ស្ថាប័នត្រួតពិនិត្យ រួមទាំងរដ្ឋសភា។
- បន្ថែមលើនេះ រាជរដ្ឋាភិបាលគប្បីពិចារណាបង្កើតលិខិតបទដ្ឋានគតិយុត្ត ឬលក្ខខណ្ឌជាកាតព្វកិច្ច ដែលគ្រប់គ្រងលើការប្រើប្រាស់ថវិកានេះ។ ជំហានបែបបុរេសកម្មនេះធានានូវការគ្រប់គ្រងថវិកានេះប្រកបដោយការទទួលខុសត្រូវ និងគណនេយ្យភាព ការជៀសវាង ការប្រើប្រាស់ធនធានមិនត្រឹមត្រូវ ហើយវិធាននេះនឹង រួមចំណែកជារួមដល់វិធាននៃគោលនយោបាយសារពើពន្ធ ។

## ថវិកាប្រតិបត្តិការសម្រាប់មន្ទីររាជធានី ខេត្ត និងក្រសួងថ្នាក់កណ្តាល

- ការចំណាយប្រតិបត្តិការដែលជាផ្នែកមួយក្នុងចំណាយចរន្ត ត្រូវបានវិភាគសម្រាប់ក្រសួងនៅថ្នាក់កណ្តាល និងមន្ទីររាជធានី ខេត្ត របស់ក្រសួង។
- ថវិកាថ្នាក់ជាតិចំនួន 83.6% ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងនៅថ្នាក់កណ្តាល ដោយថវិកាជាតិចំនួនប្រហែល 16.4% ប៉ុណ្ណោះដែលត្រូវបានបែងចែកទៅកាន់មន្ទីររាជធានី ខេត្តរបស់ក្រសួងនីមួយៗ។

### % នៃថវិកាប្រតិបត្តិការ




- មន្ទីររាជធានី ខេត្ត ត្រូវរំពឹងថានឹងដើរតួនាទីសំខាន់នៅក្នុងការផ្តល់សេវាសាធារណៈទៅដល់ប្រជាពលរដ្ឋ និងជំរុញកំណើនសេដ្ឋកិច្ច។ ប៉ុន្តែមន្ទីរមួយចំនួន ទទួលបាននូវការវិភាជថវិកាតិចជាងក្រសួងថ្នាក់កណ្តាល រួមមាន៖
    - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
    - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
    - ក្រសួងអភិវឌ្ឍន៍ជនបទ
    - ក្រសួងសាធារណៈការ និងដឹកជញ្ជូន
    - ក្រសួងទេសចរណ៍
    - ក្រសួងធនធានទឹក និងឧតុនិយម

## ថវិកាចំណាយលើលាភការ និងប្រាក់បំណាច់នៃមន្ត្រីអំណាចសាធារណៈ (គណនី 6401)៖

- ការវិភាជថវិកាប្រាក់បំណាច់មុខងារ បង្ហាញអំពីក្តីបារម្ភពាក់ព័ន្ធនឹងការប្រើប្រាស់ការចំណាយថវិកាជាតិសម្រាប់ផ្តល់ដល់មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល (6401) ដែលស្ថិតក្រោមប្រភេទនៃចំណាយបុគ្គលិក។
- ទំហំថវិកាសម្រាប់ការចំណាយនៅឆ្នាំ2023 គឺមានប្រហែល 56.72 លានដុល្លារអាមេរិកនេះបង្ហាញនូវកំណើនគួរឱ្យកត់សម្គាល់ចំពោះការចំណាយនេះ។

### % លាភការ និងប្រាក់បំណាច់នៃអំណាចសាធារណៈ




| លាភការ និងប្រាក់បំណាច់របស់មន្ត្រីសាធារណៈ | ចំនួនទឹកប្រាក់គិតជាលានរៀល | | | | | ប្រែប្រួលជា % | | | |
|---|---|---|---|---|---|---|---|---|---|
| | 2019 | 2020 | 2021 | 2022 | 2023 | 2020 | 2021 | 2022 | 2023 |
| | 170,932.5 | 189,445.1 | 211,589.7 | 217,458.4 | 226,911.2 | 11% | 12% | 3% | 4% |
| ឧទ្ទកាល័យព្រះបរមរាជវាំង | 16,800.0 | 19,200.0 | 19,200.0 | 19,200.0 | 20,400.0 | 14% | 0% | 0% | 6% |
| ប្រាក់បំណាច់ ប្រធាន អនុប្រធាន និងសមាជិកស្ថាប័នកំពូល | 42,163.1 | 41,896.2 | 41,958.3 | 43,670.1 | 43,670.4 | -1% | 0% | 4% | 0% |
| ប្រាក់បំណាច់ នាយករដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រី | 216.0 | 408.0 | 216.0 | 216.0 | 210.0 | 89% | -47% | 0% | 0% |
| ប្រាក់បំណាច់រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ | 38,672.9 | 48,470.2 | 53,538.4 | 57,392.7 | 62,154.6 | 25% | 10% | 7% | 8% |
| ប្រាក់បំណាច់អង្គទូត | 4,329.0 | 5,106.0 | 5,148.0 | 5,148.0 | 5,320.0 | 18% | 1% | 0% | 3% |
| លាភការទីប្រឹក្សា | 51,067.9 | 56,181.9 | 70,072.1 | 69,968.1 | 71,790.9 | 10% | 25% | 0% | 3% |
| លាភការជំនួយការ | 17,683.6 | 18,182.8 | 21,456.9 | 21,863.5 | 23,359.3 | 3% | 18% | 2% | 7% |

ប្រភព៖ ចំណាយថវិកាថ្នាក់ជាតិចាប់ពីឆ្នាំ 2019 ដល់ 2023

- នៅឆ្នាំ 2023 ទឹកប្រាក់ចំនួន 68% នៃថវិកាសម្រាប់ប្រាក់បំណាច់មុខងារនេះ (6401) ត្រូវបានវិភាជទាំងស្រុងទៅដល់ប្រភេទទាំងបីនេះ (27% សម្រាប់រដ្ឋមន្ត្រី រដ្ឋលេខាធិការ, អនុរដ្ឋលេខាធិការ, 31% សម្រាប់ទីប្រឹក្សា និង 10% សម្រាប់ជំនួយការ)
- ក្រសួងការពារជាតិ គឺជាក្រសួងដែលចំណាយថវិកាបំណាច់មុខងារច្រើនបំផុតចំពោះរដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ចំណែកឯក្រសួងមហាផ្ទៃ ទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋសភា គឺជាស្ថាប័នចំណាយខ្ពស់ជាងគេនូវថវិកាសម្រាប់ប្រាក់បំណាច់មុខងារទីប្រឹក្សា និងជំនួយការ។

## ការចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ថវិកានេះរាប់បញ្ចូលការចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរួមទាំងរាជធានី-ខេត្ត ក្រុង-ខណ្ឌ-ស្រុក និងឃុំ-សង្កាត់។ ការវិភាជថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិបានកើនឡើងជាបន្តបន្ទាប់ ដោយកើនឡើងពី 13% នៅឆ្នាំ2023 ទៅប្រមាណ19% នៅ2024។
- ថ្វីបើមាននិន្នាការកើនឡើងបែបនេះក្តី ភាគរយនៃការវិភាជថវិកានៅតែទាបគួរឱ្យកត់សម្គាល់ បើធៀបនឹងការចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ ដែលមានចំនួនរហូតដល់ 81% ។







### មតិយោបល់

- រាជរដ្ឋាភិបាលគប្បីបង្កើនចំណែកនៃថវិកា ដែលត្រូវវិភាជទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបង្កើនទៅដល់ 30% នៃការចំណាយប្រចាំឆ្នាំរបស់រដ្ឋ ដែល10% គប្បីត្រូវវិភាជសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំណែកឯ 10% ទៀតគប្បីត្រូវវិភាជទៅដល់រដ្ឋបាលឃុំ-សង្កាត់។ ការវិភាជថវិកាបន្ថែម នេះនឹងផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ជាតិទាំងនេះនៅក្នុងការបំពេញភារកិច្ចជាកាតព្វកិច្ចរបស់ពួកគេប្រកបដោយប្រសិទ្ធភាព និងកាត់បន្ថយភាពខ្វះខាត ក្នុងការចំណាយសម្រាប់ប្រតិបត្តិការរដ្ឋបាល និងមុខងារថ្មីៗ។
- រាជរដ្ឋាភិបាលគប្បីតាមដាន និងវាយតម្លៃប្រកបដោយប្រសិទ្ធិភាពនូវការអនុវត្តអនុក្រឹត្យលេខ 152 និង153 ដែលបានណែនាំរដ្ឋបាលឃុំសង្កាត់ និងក្រុង ស្រុកខណ្ឌវិភាជថវិកាដល់កិច្ចការសង្គមកិច្ច ការពារធនធានធម្មជាតិ និងបរិស្ថាន ព្រមទាំងការសម្របខ្លួនទៅតាមបម្រែបម្រួលអាកាសធាតុ។
- រាជរដ្ឋាភិបាលគប្បីវិភាជថវិកាកាន់តែច្រើនសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងពង្រឹងសមត្ថភាពរបស់មន្ត្រីក្នុងការគ្រប់គ្រង និងអនុវត្តថវិកាឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈកម្មវិធីកសាងសមត្ថភាពដែលឆ្លើយតបទៅនឹងតម្រូវការ។ កម្មវិធីទាំងនេះគប្បីបញ្ចូលវដ្តនៃការគ្រប់គ្រងថវិកា ការពិនិត្យតាមដាន ការវាយតម្លៃ និងការរៀនសូត្ររួមជាមួយនឹងសវនកម្មផ្ទៃក្នុង។
- រាជរដ្ឋាភិបាលគប្បីបង្កើត និងអនុវត្តប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងប្រព័ន្ធសវនកម្មផ្ទៃក្នុង សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងពេលតំណាលគ្នានេះដែរ រដ្ឋាភិបាលគប្បីធានាអោយបានធានានូវការបំពេញមុខងារ តួនាទីត្រួតពិនិត្យពេញលេញ និងប្រកបដោយប្រសិទ្ធភាពទៅលើក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងការពិនិត្យតាមដានវឌ្ឍនភាពនៃអនុវត្តថវិកា។
- រាជរដ្ឋាភិបាលគប្បីសកម្មក្នុងការលើកទឹកចិត្តការចូលរួមរបស់ប្រជាពលរដ្ឋ និងការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការរៀបចំថវិកា ដើម្បីជំរុញភាពជាម្ចាស់របស់ប្រជាពលរដ្ឋទៅលើផែនការអភិវឌ្ឍន៍មូលដ្ឋានរបស់ពួកគេ។

## រចនាសម្ព័ន្ធនៃឯកសារថវិកា



- របាយការណ៍អំពីការលទ្ធផលនៃអនុវត្តថវិកាគួរត្រូវបានបង្កើតឡើងក្នុងទម្រង់ស្របគ្នា និងអាចផ្ទៀងផ្ទាត់ជាមួយផែនការថវិកា។ រចនាសម្ព័ន្ធ ឬគណនីថវិកាដែលប្រើប្រាស់ និងកត់ត្រាក្នុងច្បាប់ស្តីពីការទូទាត់ថវិកាប្រចាំឆ្នាំ ខុសគ្នាពីរចនាសម្ព័ន្ធ ឬគណនីថវិកាក្នុងច្បាប់ថវិកាប្រចាំឆ្នាំ។

- ថវិកាចំណាយ ដែលបានកត់ត្រា ឬបង្ហាញ ក្នុងតារាង «ខ» នៃច្បាប់ស្តីពីថវិកាជាតិ ត្រូវបានចែកចេញជាប្រាំមួយប្រភេទសម្រាប់ចំណាយចរន្ត ចំណែកឯច្បាប់ស្តីពីការទូទាត់ថវិកា បានរៀបចំ និងកត់ត្រាការចំណាយនេះក្នុងទម្រង់ជាជំពូកទៅវិញ។
- តួលេខថវិកាត្រូវបាន បង្ហាញជាឯកតារូបិយវត្ថុខុសៗគ្នានៅក្នុងច្បាប់ទាំងនេះ។
- មិនបានបង្ហាញនូវតួរលេខនៃចំណាយថវិការដ្ឋទាំងស្រុងនៅក្នុងច្បាប់ថវិកា ហើយតម្រូវឲ្យធ្វើការគណនារកតួរលេខនោះ ពិតជាបង្កបញ្ហា ប្រឈមក្នុងការប្រៀបធៀប និងផ្ទៀងផ្ទាត់ នៅខណៈពេលដែលសារតួរលេខនេះបានបង្ហាញយ៉ាងច្បាស់ក្នុងឯកសារស្តីពីថវិកាសង្ខេបទៅវិញ។

## មតិយោបល់

រាជរដ្ឋាភិបាល ជាពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គប្បីពង្រឹងការយល់ដឹងជាសាធារណៈអំពីថវិកាសាធារណៈ និងតម្លាភាពនៃការអនុវត្ត ថវិកា តាមរយៈការបង្កើតក្របខណ្ឌ និងទម្រង់ជាស្តង់ដាសម្រាប់ច្បាប់ទាំងពីរប្រភេទនេះ ដែលសម្របសម្រួលដល់ការផ្ទៀងផ្ទាត់ និងការពិនិត្យមើលថវិកាឡើងវិញ។

### សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖


1. លោក ឡាំ សុជាតិ ប្រធានក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិល និងនាយកប្រតិបត្តិនៃវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ ទូរស័ព្ទ៖ 012 718 611 ឬ socheat.lam@apiinstitute.org
2. លោក ប៉ិច ពិសី អនុប្រធានក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិល និងនាយកប្រតិបត្តិនៃអង្គការតម្លាភាពកម្ពុជា ទូរស័ព្ទ៖ 089 972 620 ឬ piseypech@ticambodia.org
3. លោក ម៉ារ សុផល លេខាធិការនៃក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិល និងប្រធានកម្មវិធីនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ទូរស័ព្ទ៖ 012 845 091 ឬ sophal@ngoforum.org.kh

| ក្រសួង និងស្ថាប័ន | ការវិភាគថវិកាជា % នៃកម្ចីបរទេសសម្រាប់ការវិនិយោគសាធារណៈ | | | | | | |
|---|---|---|---|---|---|---|---|
| | ឆ្នាំ 2018 | ឆ្នាំ 2019 | ឆ្នាំ 2020 | ឆ្នាំ 2021 | ឆ្នាំ 2022 | ឆ្នាំ 2023 | ឆ្នាំ 2024 |
| រដ្ឋសភាជាតិ | 0.00 | 0.00 | 0.00 | 0.00 | 0.46 | 0.32 | 0.52 |
| ទីស្តីការគណៈរដ្ឋមន្ត្រី | 3.19 | 2.59 | 1.67 | 1.74 | 1.73 | 1.71 | 0.05 |
| ក្រសួងអធិការកិច្ច | 0.00 | 0.02 | 0.02 | 0.05 | 0.02 | 0.04 | N/A |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 0.35 | 0.61 | 0.33 | 0.16 | 0.23 | 0.31 | 0.33 |
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 0.25 | 0.53 | 0.02 | 0.49 | 0.52 | 1.40 | 1.31 |
| ស្ថាប័នប្រឆាំងអំពើពុករលួយ | 0.02 | 0.01 | 0.01 | N/A | N/A | N/A | N/A |
| ក្រសួងមុខងារសាធារណៈ | 0.01 | 0.02 | 0.64 | 0.11 | 0.02 | 0.07 | N/A |
| ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានរដ្ឋបាល | 1.04 | 1.41 | 0.11 | 0.49 | 1.55 | 1.23 | 0.85 |
| ក្រសួងយុត្តិធម៌ | 0.20 | 0.13 | 0.36 | 0.13 | 0.12 | 0.13 | N/A |
| ក្រសួងព័ត៌មាន | 0.09 | 0.05 | 7.71 | 0.12 | 0.08 | 0.15 | N/A |
| ក្រសួងសុខាភិបាល | 12.62 | 5.17 | 5.71 | 9.28 | 13.09 | 9.52 | 5.96 |
| ក្រសួងអប់រំ យុវជន និងកីឡា | 6.87 | 8.12 | 0.15 | 3.44 | 2.54 | 2.56 | 3.80 |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 0.01 | 0.20 | 0.15 | 0.15 | 0.10 | 0.13 | N/A |
| ក្រសួងបរិស្ថាន | 0.61 | 0.24 | 0.40 | 0.47 | 0.66 | 0.86 | 1.31 |
| ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា | 0.08 | 0.27 | 0.09 | 0.25 | 0.23 | 0.04 | N/A |
| ក្រសួងធម្មការ និងសាសនា | 0.01 | N/A | N/A | N/A | N/A | N/A | N/A |
| ក្រសួងកិច្ចការនារី | 0.03 | N/A | N/A | N/A | N/A | N/A | N/A |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 0.25 | 0.47 | 1.07 | 2.07 | 0.63 | 1.83 | 1.64 |
| រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | 0.19 | 0.37 | 0.66 | 0.31 | 0.00 | 0.13 | N/A |
| ក្រសួងរ៉ែ និងថាមពល | 15.45 | 8.65 | 8.33 | 12.22 | 13.53 | 6.50 | 9.04 |
| ក្រសួងពាណិជ្ជកម្ម | 1.16 | 1.34 | 2.11 | 2.62 | 2.56 | 3.18 | 0.98 |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 3.11 | 3.48 | 5.35 | 7.13 | 3.32 | 5.98 | 5.50 |
| ក្រសួងអភិវឌ្ឍន៍ជនបទ | 6.94 | 7.06 | 4.66 | 6.16 | 9.31 | 11.01 | 15.01 |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | 0.44 | 0.39 | 0.76 | 3.34 | 0.30 | 3.35 | 2.62 |
| ក្រសួងសាធារណៈការ និងដឹកជញ្ជូន | 33.71 | 39.50 | 38.47 | 31.80 | 32.16 | 32.96 | 34.29 |
| ក្រសួងទេសចរណ៍ | 0.74 | 1.19 | 1.02 | 0.79 | 0.43 | 0.49 | 0.36 |
| ក្រសួងធនធានទឹក និងឧតុនិយម | 10.68 | 11.31 | 13.27 | 10.77 | 7.08 | 7.67 | 11.13 |
| ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | 1.95 | 6.88 | 6.75 | 5.92 | 9.34 | 8.41 | 5.30 |

ប្រភព ៖ ច្បាប់ថវិកាជាតិ ឆ្នាំ២០១៨ ដល់ ២០២៤

## មតិយោបល់

- ការប្រើប្រាស់កម្ចីប្រកបដោយប្រសិទ្ធភាព គឺសំខាន់បំផុតចំពោះការធានានូវប្រយោជន៍រយៈពេលវែងរបស់កម្ចីទាំងនោះ។ រាជរដ្ឋាភិបាលគប្បីធ្វើសេចក្តីសម្រេចលើការវិនិយោគដោយពិចារណាល្អិតល្អន់ ដែលផ្តល់អាទិភាពលើការចំណាយមូលធន ដែលផ្តល់ផលត្រលប់វិញប្រកបដោយចីរភាព និងជៀសវាងគម្រោងចំណាយខ្ពស់ ( white-elephant projects ) តែបែរជាខ្វះលទ្ធភាពសម្រេចបានផលសេដ្ឋកិច្ច និងអាចរុញច្រានប្រទេសទៅក្នុងអន្ទាក់បំណុល។ មតិសាធារណៈទូទៅ បានគូសបញ្ជាក់នូវសេចក្តីត្រូវការឱ្យមានការវិភាជថវិកាបន្ថែមក្នុងចំនួនសមស្រប ដើម្បីពង្រឹងសុខុមាលភាពសង្គម និងលើកទឹកចិត្តក្រុមដែលមិនសូវទទួលបានការយកចិត្តទុកដាក់ និងងាយរងគ្រោះ រួមទាំងស្ត្រី កុមារ និងមនុស្សចាស់។
- រាជរដ្ឋាភិបាលគប្បីប្រើប្រាស់កម្ចីជាលក្ខណៈយុទ្ធសាស្ត្រ ដើម្បីបង្កើតភាពរីកចម្រើនរយៈពេលវែងលើផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ច។ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់ គឺជារឿងសំខាន់ ដើម្បីពង្រឹងការភ្ជាប់ទំនាក់ទំនង និងភាពប្រកួតប្រជែងសេដ្ឋកិច្ច តាមរយៈការកាត់បន្ថយបន្ទុកចំណាយផ្នែកភស្តុភារ និងផលិតកម្ម។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគប្បីកើតឡើងទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងគម្រោងនៅថ្នាក់ឃុំសង្កាត់ ដូចជា បណ្តាញដឹកជញ្ជូន ការផ្គត់ផ្គង់ទឹក អគ្គិសនី និងការតភ្ជាប់ប្រព័ន្ធអ៊ីនធឺណិត។
- ការអនុវត្តគោលនយោបាយដែលមិនអត់ឱនចំពោះអំពើពុករលួយ គឺ ចាំបាច់នៅក្នុងការគ្រប់គ្រងថវិកាសាធារណៈជាពិសេសក្នុងដំណើរការលទ្ធកម្មសាធារណៈ។ ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព និងសវនកម្មឯករាជ្យទៅលើថវិកា គឺជាការចាំបាច់ ដើម្បីការពារប្រឆាំងនឹងអំពើមិនសមស្រប និងធានាតម្លាភាព។

ឯកតា លានរៀល

| ការវិភាជចំណាយថវិកាប្រតិបត្តិការឆ្នាំ 2024 គិតជាភាគរយ (%) សម្រាប់ក្រសួងថ្នាក់កណ្តាល និងមន្ទីររាជធានី ខេត្ត | | | | | |
|---|---|---|---|---|---|
| សេចក្តីបរិយាយ | ចំនួនទឹកប្រាក់ | % | សេចក្តីបរិយាយ | ចំនួនទឹកប្រាក់ | % |
| សរុបរួមចំណាយប្រតិបត្តិការ | 3433659.9 | | ក្រសួងធម្មការ និងសាសនា | 19039.8 | |
| សរុបចំណាយប្រតិបត្តិការក្រសួងថ្នាក់កណ្តាល | 2871210.6 | 83.6 | ក្រសួងថ្នាក់កណ្តាល | 8438.0 | 44.3 |
| សរុបចំណាយប្រតិបត្តិការមន្ទីររាជធានី ខេត្ត | 562449.3 | 16.4 | មន្ទីររាជធានី ខេត្ត | 10601.8 | 55.7 |
| ក្រសួងអធិការកិច្ច | 22451.0 | | ក្រសួងកិច្ចការនារី | 23883.0 | |
| ក្រសួងថ្នាក់កណ្តាល | 10498.0 | 46.8 | ក្រសួងថ្នាក់កណ្តាល | 98910.0 | 41.4 |
| មន្ទីររាជធានី ខេត្ត | 11953.0 | 53.2 | មន្ទីររាជធានី ខេត្ត | 13992.0 | 58.6 |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 179669.5 | | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 98885.0 | |
| ក្រសួងថ្នាក់កណ្តាល | 161507.5 | 89.9 | ក្រសួងថ្នាក់កណ្តាល | 81423.8 | 82.3 |
| មន្ទីររាជធានី ខេត្ត | 18162.0 | 10.1 | មន្ទីររាជធានី ខេត្ត | 17461.2 | 17.7 |
| ក្រសួងផែនការ | 25780.0 | | ក្រសួងរ៉ែ និងថាមពល | 28119.0 | |
| ក្រសួងថ្នាក់កណ្តាល | 12940.0 | 50.2 | ក្រសួងថ្នាក់កណ្តាល | 15500.0 | 55.1 |
| មន្ទីររាជធានី ខេត្ត | 12840.0 | 49.8 | មន្ទីររាជធានី ខេត្ត | 12619.0 | 44.9 |
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 30602.0 | | ក្រសួងពាណិជ្ជកម្ម | 49745.0 | |
| ក្រសួងថ្នាក់កណ្តាល | 17835.0 | 58 | ក្រសួងថ្នាក់កណ្តាល | 36207.0 | 72.8 |
| មន្ទីររាជធានី ខេត្ត | 12767.0 | 42 | មន្ទីររាជធានី ខេត្ត | 13538.0 | 27.2 |
| ក្រសួងមុខងារសាធារណៈ | 22283.0 | | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 99576.2 | |
| ក្រសួងថ្នាក់កណ្តាល | 8985.0 | 40.3 | ក្រសួងថ្នាក់កណ្តាល | 63619.2 | 63.9 |
| មន្ទីររាជធានី ខេត្ត | 13298.0 | 59.7 | មន្ទីររាជធានី ខេត្ត | 35957.0 | 36.1 |
| ក្រសួងយុត្តិធម៌ | 85374.0 | | ក្រសួងអភិវឌ្ឍន៍ជនបទ | 172522.0 | |
| មន្ទីររាជធានី ខេត្ត | 44967.0 | 53 | ក្រសួងថ្នាក់កណ្តាល | 140288.0 | 81.3 |
| ក្រសួងព័ត៌មាន | 37008.0 | | មន្ទីររាជធានី ខេត្ត | 32234.0 | 18.7 |
| ក្រសួងថ្នាក់កណ្តាល | 23554.0 | 63.6 | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | 82035.0 | |
| មន្ទីររាជធានី ខេត្ត | 13454.0 | 36.4 | ក្រសួងថ្នាក់កណ្តាល | 70218.0 | 85.6 |
| ក្រសួងសុខាភិបាល | 170971.0 | | មន្ទីររាជធានី ខេត្ត | 11817.0 | 14.4 |
| ក្រសួងថ្នាក់កណ្តាល | 163040.0 | 95 | ក្រសួងសាធារណការ និងដឹកជញ្ជូន | 355758.0 | |
| ក្រសួងអប់រំ យុវជន និងកីឡា | 326312.9 | | ក្រសួងថ្នាក់កណ្តាល | 336347.0 | 94.5 |
| មន្ទីររាជធានី ខេត្ត | 166130.3 | 51 | មន្ទីររាជធានី ខេត្ត | 19411.0 | 5.5 |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 29656.2 | | ក្រសួងទេសចរណ៍ | 35112.0 | |
| ក្រសួងថ្នាក់កណ្តាល | 16111.2 | 54 | ក្រសួងថ្នាក់កណ្តាល | 22725.0 | 64.7 |
| មន្ទីររាជធានី ខេត្ត | 13545.0 | 46 | មន្ទីររាជធានី ខេត្ត | 12387.0 | 35.3 |
| ក្រសួងបរិស្ថាន | 31996.0 | | ក្រសួងធនធានទឹក និងឧតុនិយម | 132411.0 | |
| ក្រសួងថ្នាក់កណ្តាល | 17935.0 | 56.1 | ក្រសួងថ្នាក់កណ្តាល | 109324.0 | 82.6 |
| មន្ទីររាជធានី ខេត្ត | 14061.0 | 43.9 | មន្ទីររាជធានី ខេត្ត | 23087.0 | 17.4 |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 33553 | | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | 30897.0 | |
| ក្រសួងថ្នាក់កណ្តាល | 15559.0 | 46 | ក្រសួងថ្នាក់កណ្តាល | 18655.0 | 60.4 |
| មន្ទីររាជធានី ខេត្ត | 17994.0 | 54 | មន្ទីររាជធានី ខេត្ត | 12242.0 | 39.6 |

ប្រភព ៖ ច្បាប់ថវិកាជាតិឆ្នាំ 2024

| លាភការ និងប្រាក់បំណាច់នៃអំណាចសាធារណៈ ( ឯកតា លានរៀល ) | | | | | | |
|---|---|---|---|---|---|---|
| សេចក្តីបរិយាយ | រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ( 64014 ) | | ទីប្រឹក្សា ( 64016 ) | | ជំនួយការ ( 64018 ) | |
| **សរុបរួមចំណាយ ២០២៣** | **62,154.6** | % | **71,790.9** | % | **23,359.3** | % |
| រាជធានី ខេត្ត | | 0.00% | 29.3 | 0.04% | | 0.00% |
| 01-ព្រះបរមរាជវាំង | 598.0 | 0.96% | 6,402.0 | 8.92% | 610.0 | 2.61% |
| 02-រដ្ឋសភា | 386.0 | 0.62% | 8,230.3 | 11.46% | 4,920.2 | 21.06% |
| 03-ព្រឹទ្ធសភា | 355.0 | 0.57% | 2,1116.0 | 2.95% | 218.0 | 0.93% |
| 04-ក្រុមប្រឹក្សាធម្មនុញ្ញ | 235.0 | 0.38% | 612.0 | 0.85% | 281.0 | 1.20% |
| 05.1-ទីស្តីការគណៈរដ្ឋមន្ត្រី | 4,317.6 | 6.95% | 13,230.4 | 18.43% | 7,339.9 | 31.42% |
| 05.3-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | 765.6 | 1.23% | 360.4 | 0.50% | 219.6 | 0.94% |
| 06-ក្រសួងការពារជាតិ | 13,825.0 | 22.24% | | 0.00% | | 0.00% |
| 07.1-ក្រសួងមហាផ្ទៃសន្តិសុខសាធារណៈ | 1,873.3 | 3.01% | 4,673.6 | 6.51% | | 0.00% |
| 07.2-ក្រសួងមហាផ្ទៃរដ្ឋបាលទូទៅ | 1,608.0 | 2.59% | 13,283.9 | 18.50% | 820.4 | 3.51% |
| 08-ក្រសួងទំនាក់ទំនងជាមួយ រដ្ឋសភា ព្រឹទ្ធសភា | 1,041.6 | 1.68% | 1,132.2 | 1.58% | 670.3 | 2.87% |
| 09-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | 890.4 | 1.43% | 242.6 | 0.34% | 86.0 | 0.37% |
| 10-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 1,821.6 | 2.93% | 607.2 | 0.85% | 167.3 | 0.72% |
| 11-ក្រសួងព័ត៌មាន | 2,317.6 | 3.73% | 5,444.9 | 7.58% | 79.6 | 0.34% |
| 12-ក្រសួងសុខាភិបាល | 2,167.2 | 3.49% | 948.0 | 1.32% | 49.2 | 0.21% |
| 13-ក្រសួងរ៉ែ និងថាមពល | 1,328.4 | 2.14% | 184.4 | 0.26% | 146.5 | 0.63% |
| 14-ក្រសួងផែនការ | 1,172.4 | 1.89% | 2,059.2 | 2.87% | 1,053.4 | 4.51% |
| 15-ក្រសួងពាណិជ្ជកម្ម | 1,581.6 | 2.54% | 729.3 | 1.02% | 479.6 | 2.05% |
| 16.1-ក្រសួងអប់រំ យុវជន និងកីឡា | 1,303.2 | 2.10% | 1,102.8 | 1.54% | 173.6 | 0.74% |
| 17-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 1,776.0 | 2.86% | 761.5 | 1.06% | 303.6 | 1.30% |
| 18-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 950.5 | 1.53% | 547.6 | 0.76% | 689.0 | 2.95% |
| 19-ក្រសួងបរិស្ថាន | 1,206.0 | 1.94% | 297.6 | 0.41% | 973.3 | 4.17% |
| 20-ក្រសួងអភិវឌ្ឍន៍ជនបទ | 1,414.6 | 2.28% | 677.0 | 0.94% | 175.0 | 0.75% |
| 21-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 1,603.6 | 2.58% | 1,035.3 | 1.44% | 118.1 | 0.51% |
| 22-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | 1,588.8 | 2.56% | 449.8 | 0.63% | 569.9 | 2.44% |
| 23-ក្រសួងធម្មការ និងសាសនា | 1,311.6 | 2.11% | 394.0 | 0.55% | 151.7 | 0.65% |
| 24-ក្រសួងកិច្ចការនារី | 968.8 | 1.56% | 245.7 | 0.34% | 1.7 | 0.01% |
| 25-ក្រសួងសាធារណៈការ និងដឹកជញ្ជូន | 2,071.2 | 3.33% | 454.8 | 0.63% | 670.8 | 2.87% |
| 26.1-ក្រសួងយុត្តិធម៌ | 757.9 | 1.22% | 301.4 | 0.42% | 653.6 | 2.80% |
| 26.2-តុលាការកំពូល | 14.4 | 0.02% | | 0.00% | | 0.00% |
| 26.4-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | 162.0 | 0.26% | | 0.00% | | 0.00% |
| 27-ក្រសួងទេសចរណ៍ | 1,672.8 | 2.69% | 795.6 | 1.11% | 529.2 | 2.27% |
| 28-ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ | 1,188.0 | 1.91% | 460.8 | 0.64% | 326.4 | 1.40% |
| 29-ក្រសួងធនធានទឹក និងឧតុនិយម | 996.0 | 1.60% | 262.8 | 0.37% | 51.6 | 0.22% |
| 31-អជ្ញាធរសវនកម្មជាតិ | 819.0 | 1.32% | 108.9 | 0.15% | | 0.00% |
| 32-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 1,627.6 | 2.62% | 2,876.2 | 4.01% | 178.8 | 0.77% |
| 33-អង្គភាពប្រឆាំងអំពើពុករលួយ | 1,684.3 | 2.71% | | 0.00% | 255.9 | 1.10% |
| 34-ក្រសួងមុខងារសាធារណៈ | 1,370.4 | 2.20% | 338.4 | 0.47% | 43.2 | 0.18% |
| 35-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | 1,383.6 | 2.23% | 395.0 | 0.55% | 352.9 | 1.51% |